«ស្អប់ឬស្រលាញ់?»

ព្រឹកព្រហាមស្រាងៗ...លេខាប៉េងហុចលុយទៅឲ្យដៃជើងដែលឈរជាជួរ រង់ចាំបើករង្វាន់បន្ទាប់ពី បានសម្ដែងល្ខោនបង្កកំហឹងរវាងបុរសអ្នកលេងនិងនារីអ្នកច្បាប់ រួចរាល់។
«ឯងច្បាស់ហើយថាគ្មានអាណាម្នាក់ថ្លោះការណ៍ឲ្យអ្នកប្រុសចាប់ថ្នាក់បានទេ! ឮ??»
«គ្មានទេហ៊ា! អ្នកប្រុសយុត្តនាជឿស្លុងហើយ»
«ហើយគេឲ្យពួកឯងធ្វើម៉េច?»
«គាត់ឲ្យប្រគល់អាប្អូននាក់នេះឲ្យប៉ូលិស ពីបទជិះតាមរំខានគាត់! គឺអ្នកប្រុសចង់មកវិញធ្វើពើមិនដឹងរឿង!»
«គេខឹងផ្ទះនោះអត់អញ្ចឹង?»លេខាប៉េងចងចិញ្ចើមសួរ។
«មិនដឹងដែរព្រោះអ្នកប្រុសមិននិយាយ! តែប្រាកដជាខឹងហើយខឹងជាងគេគឺស្រីមេធាវីនោះ»
«ល្អហើយ! ការងារចប់ហើយ! យកលុយទៅចាយហើយបិទមាត់ឲ្យជិត!»
«បាទ! ហ៊ា!»
លេខាប៉េងចូលទៅក្នុងផ្ទះធំរបស់អគ្គទេសាភិបាលបាត់ទុកឲ្យពួក អាម៉ីអាថោងនៅចែកលុយគ្នាហ៊ោសប្បាយឯរោងម៉ាស៊ីនខាងក្រោយដោយចំហ ព្រោះគេអាងថាកូនប្រុសធម៌ទាំងបីកម្រមកដល់ទីនេះណាស់លើកលែងតែ ត្រូវឪពុកហៅ។
តែលើកនេះគេស៊យបន្តិចហើយព្រោះស្រមោលខ្ពស់មួយបានចាកចេញទៅតំណាល នឹងលេខាប៉េងដែរ។ បានន័យថាការសន្ទនាទាំងប៉ុន្មានទំនងជាត្រូវបានជននោះត្រងត្រាប់ យល់អស់គ្មានចន្លោះទេ....

រាត្រីកាលឈានចូលមកដល់សាជាថ្មី.....
នៅក្នុងបរិវេណអតីតរបងរោងចក្រឆេះមួយដែលត្រូវបានថៅកែបោះបង់ចោល ព្រោះតែក្ស័យធនជាយូរមកហើយបច្ចុប្បន្នវាបានក្លាយមកជាឃ្លាំង ទំនិញចាស់ៗគួរឲ្យខ្លាចរអាបើចូលទៅតែម្នាក់ឯង។ ស្រមោលមនុស្សបីបួននាក់ ដែលមានកាយវិការស្វាហាប់រឹងមាំ បោះជំហានវែងៗឆ្លងកាត់ទ្វារតូចខាងក្រោយដែលដុះស្មៅស៊ុបទ្រុប ហើយមកដល់បរិវេណខាងក្នុងគេនាំគ្នារត់សំដៅរកឃ្លាំងនោះទាំងមាន កាន់កាំភ្លើងក្នុងដៃម្នាក់មួយដូចកុនហុងកុង។
ម្នាក់នៅមុខគេលូកកែងដៃរុញទ្វារឃ្លាំងរបើកបង្កជាសំឡេងង៉ឺត នៃទ្វារដ៏ចាស់ដែលត្រូវបានទុកចោលហាលខ្យល់ហាលភ្លៀងជាច្រើន ឆ្នាំ។

ពន្លឺពណ៌លឿងស្រាលគ្របដណ្តប់បានតែផ្នែកខ្លះក្នុងឃ្លាំងនោះ ព្រោះថាវាជះចេញមកពីអំពូលពងមាន់តូចមួយដែលព្យួរកណ្ដាលកន្លោង ហើយរេចុះឡើងទៅតាមកម្លាំងខ្យល់។ ចំពីក្រោមអំពូលនោះបុរសមាឌធំមាំម្នាក់អង្គុយលើកៅអីដោយដៃ ត្រូវចងស្លាបសេកទៅក្រោយក្នុងស្ថានភាពដូចជាប់ពិរុទ្ធឬត្រូវគេ បង្ខាំងនៅទីនេះ។
ខ្មាន់កាំភ្លើងសសៀរចូលមកជាបន្តបន្ទាប់កាន់តែជិត ហើយម្នាក់នៅនឹងមុខគេនោះលូកដៃដោយប្រយ័ត្នប្រយែងទៅរកស្មាអ្នក ជាប់ឃុំ។
«Hey Johan?»
គេហៅតិចៗហើយទាញបំបែរជនមាឌធំមករកខ្លួនដើម្បីមើលមុខឲ្យច្បាស់ ផង....តែមិនដឹងយ៉ាងម៉េចបានជាអ្នកអង្គុយនោះបែរមកចំ បែរជាខ្មាន់កាំភ្លើងតក់ស្លុតញ័រដៃហើយថយក្រោយមួយជំហាន ទុកឲ្យអ្នកដែលអង្គុយដូចជាប់ចំណងនោះរលាស់ដៃក្រោកឈរហើយសើចចិញ្ចាច។
ពន្លឺពណ៌ពងមាន់ចាំងឆ្វាចលើស្នាមខួចចុងមាត់របស់គេ ព្រមពេលភ្លើងជាច្រើនទៀតក្នុងឃ្លាំងត្រូវបានបំភ្លឺមករាលដាល ពាសពេញបរិវេណនេះឲ្យភ្លឺច្បាស់ដូចថ្ងៃ។ ខ្មាន់ទាំងបួនរេភ្នែកសម្លឹងក្រុមមនុស្សលាក់ខ្លួនពីក្រោយបារ អីវ៉ាន់ដែលបង្ហាញខ្លួនមកជាង១០នាក់ ពួកគេរកតែកម្រើកកាំភ្លើងតែមេរបស់គេត្រូវបុរសបន្លំខ្លួនជាអ្នក ទោសទាត់ទម្លាក់អាវុធពីដៃបានតាំងពីវិនាទីដំបូងទៅហើយ។
«ដាក់កាំភ្លើង បើចង់រស់!»
គេនិយាយតិចៗតែក្នុងន័យបញ្ជា ហើយមាត់គេញញឹមតែជាស្នាមញញឹមមិនល្អប៉ុន្មានដែរ។
«បងយុត្តនា! ម៉េចបានជា...ម៉េចបានជា...?»មេខ្មាន់កាំភ្លើងសួរផងបកដៃឲ្យសញ្ញាកូនចៅទម្លាក់កាំភ្លើងរាបដល់ដីផង។
គ្នីគ្នាយុត្តនាចុះមកដល់ប្រមូលអាវុធសត្រូវទុកអស់ ។ ចំណែកបុរសមេកោយក្រពាត់ដៃអង្គុយជំទែងលើកៅអីនោះវិញ៖
«ឯងរកអ្នកណា? មកកន្លែងខ្ញុំ មិនមែនរកខ្ញុំទេ?»
ជននោះរញ្ជីរញ្ជ័រព្រោះដឹងថាខ្លួននៅក្នុងសភាពទ័លច្រក៖
«គឺ...គឺ....»
គេទីទើរបន្តិចហើយក៏លុតជង្គង់តាមរបៀបពួកជនពាលប្រឈមមុខនឹង ស្ថានភាពគ្រោះដល់ជីវិត។គេលន់តួសុំទុកឱកាសរស់ទាំងញ័រដៃជើង៖

«បងខ្ញុំត្រូវគេប្រើទេ!...»
មេខ្នាន់កាំភ្លើងស្រាប់តែយំហ៊ូដូចស្រី ធ្វើឲ្យកូនចៅបីនាក់ទៀតទន់ជង្គង់លុតដល់ដីតាមគ្នាព្រាត។
«អញ្ចឹងប្រាប់មុខអ្នកដែលប្រើឯងនោះមក!»
សំឡេងគេត្រជាក់ដូចទឹកមុខរបស់គេ តែចិត្តគេក្ដៅព្រោះជាមនុស្សឆេវឆាវស្រាប់ហើយ។ មិនបាច់ស្ដាប់ពាក្យសារភាពក្នុងចិត្តគេក៏ដឹងស្រេចហើយថាអ្នកណា ជាអ្នកនៅពីក្រោយរឿងនេះ គេហើបមាត់សួរគ្រាន់តែចង់បញ្ជាក់ប៉ុណ្ណោះ។
«គឺ....គឺ....ចៅហ្វាយ....ចៅហ្វាយ....»
«អ្នកណាជាចៅហ្វាយឯង?»
«ប៉ែន ពេជ្រប្រាថ្នា!»
យុត្តនាសើចខឹក៖
«ស្មានអីចេះខុស!»
«កុំសម្លាប់ខ្ញុំបង! ខ្ញុំត្រូវគេបង្ខំមកទេ!»
«វាចង់សម្លាប់បំបិទមាត់រឿងវាបោកឪខ្លួនឯង?»យុត្តនាសួរដោយមុខស្មើ។
«បាទ!...ហើយ...ហើយមួយទៀត....»
«និយាយឲ្យអស់មក!»
«បងសន្យាទៅថាឲ្យពួកខ្ញុំរួចបានខ្ញុំនិយាយ!»
យុត្តនាសើចទៀតធ្វើឲ្យខ្នាន់កាំភ្លើងឡិងឡង់៖
«បងសើចធ្វើអី?»
«សើចថាឯងល្ងង់ម្លឹងៗចង់ចេញដើរធ្វើអ្នកលេងនឹងគេដែរ?»
«ពួកខ្ញុំអត់មានមេទេ មានតែយកគាត់ធ្វើខ្នង បើបងទុកខ្ញុំរស់ខ្ញុំសន្យាដើរតាមបងពីយប់នេះទៅ ពួកខ្ញុំទាំងបួននាក់!»

យុត្តនារភ្នែកសម្លឹងក្មេងស្ទាវទាំងបួន។ ពួកគេគឺកំព្រាគ្មានឪពុកម្ដាយដូចខ្លួនប្រាកដណាស់ គ្រាន់តែគេសំណាងមិនល្អត្រង់ថាគ្មានឪពុកធម៌ជួយពីក្រោយប៉ុណ្ណោះ។ ស្ថានភាពពួកគេបើមិនញៀនល្បែងក៏ញៀនថ្នាំដែរបានជាត្រូវអ្នកមាន សុភាពបុរសក្លែងក្លាយហៅមកប្រើបាន។
«បាន!»

ពួកគេនោះអរជាខ្លាំង គ្រាន់តែឃើញឫកពាក៏យុត្តនាអាចដឹងបាន។
«អរគុណបង! តាមពិតគឺ ប៉ែន ពេជ្រប្រាថ្នា មិនមែនចង់សម្លាប់តែចូហានបំបិទមាត់ទេ គឺចង់យករឿងនេះបង្វែរដាក់បងទាំងអស់ហើយប្ដឹងបងឡើងតុលាការ!»
«ប្ដឹង?»
យុត្តនាលើកចិញ្ចើមសើចមួយយ៉ាងស្រស់សង្ហា ព្រោះមិនជឿត្រចៀកខ្លួនឯងនូវល្បិចគួរឲ្យអស់សំណើចនេះ។
តែខ្មាន់កាំភ្លើងវ័យស្មាវពន្យល់បន្ថែម៖
«គេចង់ឲ្យបងក្លាយជាអ្នកនៅពីក្រោយរឿងបោកលុយ១១លាន ហើយបងអ្នកចាប់បង្ខាំងចូហាននិងសម្លាប់វាបំបិទដានទៀត!»
យុត្តនាឈ្ងោកមុខញញឹម គេអង្អែលកាំភ្លើងក្នុងដៃមាត់និយាយ៖
«សាហាវមែនហ្ន៎! ល្បិចអញ្ចឹងក៏រកនឹកឃើញដែរកូនឧកញ៉ា!»
ស្មាវខ្មាន់កាំភ្លើងបន្ថែមភ្លាម៖
«គេជាគ្រួសារអ្នកធំមានម្ដាយជាជំទាវ ឪពុកជាឧកញ៉ាហើយប្អូនគេមេធាវីទៀត.....»
ឃ្លាចុងក្រោយនេះហាក់ដូចជាមានចេតនាចាប់អារម្មណ៍ពីការពាក់ព័ន្ធ របស់ពៅបញ្ញាទៅក្នុងគម្រោងការនេះ។ គេទម្លាក់ទឹកមុខក្រឡេកកន្ទុយភ្នែកសម្លឹងដីទុក ឱកាសឲ្យខួរក្បាល ពិចារណា។
«នាងមិនដឹងគុណថែមទាំងរកល្បិចជួយបងប្រុសហើយជួយលាងរឿងទៀត! ស្មានថាចូហានស្លាប់បាត់បងប្រុសសំអុយរបស់នាងរួចខ្លួន ហើយឪពុកនាងលែងបានដឹងឮរឿងអាក្រក់អស់នេះរបស់កូនប្រុសច្បងគាត់? ហើយនាងគេចពីជំពាក់ខ្ញុំរួចដោយអូសកខ្ញុំចូលទ្រុងងាយៗអញ្ចឹង ពៅបញ្ញា?»
គេសើចស្ញើៗ....
«ចុះឯងថ្លោះការអញ្ចឹង ឯងគិតទៅជួបប្រាប់មេឯងវិញថាម៉េច?»
«អត់បាច់ទេព្រោះខ្ញុំមានមេថ្មីហើយ!»
«ខ្ញុំអាចប្រើមនុស្សថ្លោះការដូចពួកឯងដែរ?»
ស្មាវទម្លាក់ទឹកមុខ តែយុត្តនាសើច៖
«មិនបាច់ភ័យទេ! និយាយលេងផងមិនបាន!? មានការងារឲ្យធ្វើ......បើឯងថ្លោះការទៀតអាហ្នឹងព្រះក៏មិនដឹងជួយឯងអាម៉េចដែរ....!»

អ្នកប្រុសទីមួយក្រោកចាកចេញទៅពីក្រោមសភាពត្រេកអររបស់ស្ទាវអ្នកលេងទាំងបួនដែលដៀងភ្នែកមើលមុខគ្នាជាសម្ងាត់។

យុត្តនាបោះជំហានចេញតម្រង់រថយន្ត ដែលលាក់បំពួនក្នុងគុម្ពោតព្រៃក្រាស់ពីក្រោយឃ្លាំង។បើកុំតែគេចុច បញ្ជាបើកសោពីចម្ងាយ គ្មានអ្នកណាដឹងថាមានរថយន្តទំនើបមួយនៅទីនោះឡើយ។ ជើងគេជាន់លើស្មៅសើមរអិលដែលដក់ទឹកភ្លៀងច្រើនថ្ងៃមកហើយ តែគេមិនខ្វល់ឡើយព្រោះចិត្តកំពុងសៅហ្មង។ អ្នកប្រុសរអ៊ូតិចៗម្នាក់ឯងដោយទឹកមុខសោះកក្រោះ៖
«ស្រីអាត្មានិយម!»
ប្រហែលមិនមានតែគេខ្លួនឯងទេដែលដឹងថា គេកំពុងចង់សំដៅលើអ្នកណា។
.....យុត្តនាលូកដៃទាញបើកទ្វារឡានតែចិត្តមិននៅទីនេះឡើយ។ រូបរាងនារីអ្នកច្បាប់អណ្តែតមកពេញក្នុងបេះដូង មិនប្រាកដថាស្អប់ឬស្រលាញ់ទេ ដែលច្បាស់ក្នុងពេលនេះគឺគេខឹងនាង។
គេបញ្ឆេះឡានហើយដាក់លេខថយព្រមទាំងងាកមកក្រោយមើលផ្លូវ ស្រាប់តែជាន់ហ្វ្រាំងម៉ឺតដោយភ្ញាក់ផ្អើល។
«ចូលមកសំងំក្នុងឡានតាំងពីថ្មើរណា?»
«បើកចេញទៅកុំឲ្យពួកនោះឃើញ»រិទ្ធិនិយាយមួយៗទាំងញញឹម។ យុត្តនាដកដង្ហើមយូរហើយគ្រវីក្បាលដោយហួសចិត្តដៃបញ្ជាចង្កូត បណ្តើរ។
«មកដល់ពីអង្កាល់! ធ្វើលឺបលធ្វើអី?» អ្នកលេងរូបស្រស់វាចាទាំងទឹកមុខមិនស្រស់ស្រាយព្រោះមានវិបត្តិ។
រិទ្ធិនិយាយតប៖
«ទើបចូលមកពេលឯងចុចឡានបញ្ជាហ្នឹងហើយ! អារម្មណ៍មិននៅខ្លួនទេ? គេលួចចូលឡានក៏មើលមិនឃើញ!»
ឡានចេញមកដល់មាត់ទ្វាររបងល្មម។ អ្នកប្រុសធំជាន់ហ្គែបន្ថែមល្បឿនស្របពេលសំណួររិទ្ធិធ្វើឲ្យគេ នឹកឃើញដល់ពាក្យពេចន៍ក្មេងស្ទាវខ្មាន់កាំភ្លើង។
«មិនមែនគ្រាន់តែមិននៅខ្លួនទេ គឺអារម្មណ៍ហោះទៅសម្លាប់មនុស្ស!»
គេនិយាយតាមចិត្តដូចតែរាល់ដង ព្រោះថាអ្នកប្រុសយុត្តនាគិតយ៉ាងណាគឺនិយាយយ៉ាងនោះហើយ។ ឃើញតែសន្ទុះឡានគេក៏ដឹងគេកំពុងមួហ្មងកម្រិតណាដែរ។ រិទ្ធិគ្រហែម

សម្រួលបរិយាកាស៖
«ក្មេងពាលអស់នោះនិយាយពីរបីម៉ាត់ឯងជឿភ្លាមយុត្តនា?»
យុត្តនាទើបតែដឹងថារិទ្ធិក៏បានឃើញទិដ្ឋភាពទាំងអស់នៅក្នុង ឃ្លាំងអម្បាញ់មិញដែរ។ ចំណែកសំណួរគេនៅពេលនេះទៀត ធ្វើឲ្យនាយកាន់តែយល់ថា រិទ្ធិហាក់លំអៀងកាន់ជើងផ្ទះសត្រូវដែលគេកំពុងទៅបង្កប់ខ្លួន។
គេញាក់ស្មាសើចចំអក៖
«ហើយបើមិនជឿពួកវាទៅជឿមនុស្សផ្ទះនោះ?»
មិនឃើញរិទ្ធិឆ្លើយ អ្នកប្រុសធំសើចជូរចត់ហើយបន្តកំបុត៖
«ពិសេសអ្នកនាងតូចរបស់ឯង!»
«មានទាក់ទងអីជាមួយពៅបញ្ញា?»
គេសួរវិញភ្លាម ធ្វើឲ្យយុត្តនារវែកភ្នែកដែលពោរពេញដោយភាពឆ្មើងឆ្មៃសម្លឹងមករក រិទ្ធិតាមកញ្ចក់ ជាកាយវិការបង្ហាញថាសំណួរនេះធ្វើឲ្យគេហួងសៅកាន់តែខ្លាំង។

រិទ្ធិនៅស្ងៀមព្រោះដឹងថាចិត្តគេកំពុងក្តៅងំតែអ្នកប្រុសទី ពីររវែកភ្នែកគិត។ កាលពីព្រឹកគេបានលបឃើញលេខាប៉េងហុចលុយរង្វាន់ទៅឲ្យពួកកូនចៅ របស់យុត្តនា។ គេដឹងថាលេខានេះកំពុងធ្វើអ្វីម្យ៉ាងពិសេសគឺបង្កគំនុំរវាង យុត្តនានិងផ្ទះប៉ែនពេជ្រឲ្យកាន់តែជ្រៅ ។ មិនស្មានថាយប់នេះទៀតសោតគេជួបរឿងទាក់ទងនឹងផ្ទះនោះសាជាថ្មី ហើយធ្ងន់ជាងមុនទៅទៀត។ សភាពរបស់យុត្តនាគឺសៅហ្មងចងអាឃាត ឯចំណុចស៊ីបរបស់គេប្រាកដជាស្រីតូចដែលដែលនៅជំពាក់សម្តីគេ។
តើលេខាប៉េងធ្វើរឿងយប់នេះដែរ? ឬមនុស្សទាំងនោះពិតជា ប៉ែន ពេជ្រប្រាថ្នា បញ្ជូនមក? ក្នុងចំណោមពីរនាក់នេះ អ្នកណាឲ្យប្រាកដដែលលេងល្បែនបំផ្លាញទំនុកចិត្តរវាងយុត្តនា និងពៅបញ្ញា?
«ម៉េចឯងមកដល់ទីនេះ?»យុត្តនាសួរកាត់ផ្តាច់ការរិះគិតរបស់អ្នកបង្កប់ខ្លួន។
ជំនួយការរិទ្ធិតបវិញស្មើៗ៖
«មកតាមឯង!»
យុត្តនាសម្លឹងគេតាមកញ្ចក់សាជាថ្មី។ វាហាក់គ្មានហេតុផលពេកហើយសម្រាប់ការឆ្លើយតបនេះ គេសើចញាក់ស្មាផង។

«ខ្លាចឯងចាញ់បញ្ឆោតគេបានជាខំតាមមក!»
គេនិយាយបន្ថែម ព្រោះឃើញគូសន្ទនាកំពុងចម្លែកចិត្ត។
«អញ្ចឹង?»
យុត្តនាសួរឌឺ។ មិនឃើញសុភាពបុរសហើបមាត់ គេបន្តទៀតភ្លាម៖
«មែនទែនទៅ ឯងនិងខ្ញុំ តើអ្នកណាចាញ់បោកគេឲ្យប្រាកដទៅរិទ្ធិ?»
រិទ្ធិផ្អែកដៃទាំងពីរច្រងាងលើពូកឡានខាងក្រោយ។ អាវធំដ៏ថ្លៃថ្នូររបស់គេសក្តិសមណាស់ជាមួយតួនាទីជនបង្កប់ជា ជំនួយការដ៏រាបសា ហើយគ្មានអ្នកណាដឹងថាថ្មើរណេះគេនៅជាមួយអ្នកលេងមុខស្រស់ទេ។ គេវាចាតិចៗតបវិញ៖
«បើគេប្រើមកមែនម៉េចក៏ភ្លាត់ការណ៍អីងាយម៉េះ? សភាពការណ៍ក្នុងឃ្លាំងអំបាញ់មិញ ដូចជាគេមានចេតនាឲ្យឯងចាប់បាន ហើយនិយាយមួយបង្កាច់កូនៗរបស់ប៉ែនពេជ្រ»
យុត្តនាសើចខឹកៗជាកាយវិការព្រងើយនឹងការវិភាគរបស់បងប្អូនធម៌។
សន្ទុះចិត្តមានះព្រោះតែកំហឹងលើស្រីម្នាក់ដែលស្ថិតនៅក្នុង បេះដូងខ្លួន ហើយដែលចែកមិនដាច់ថាស្រលាញ់ឬស្អប់ បានធ្វើឲ្យគេមើលរំលងសម្តីជាស់តឿនរបស់រិទ្ធិ។
«ឯងយល់ថា ខ្ញុំអន់ដល់ថ្នាក់ទុកឲ្យពួកគេលេងស្រួលៗ!»
រិទ្ធិនៅស្ងៀម ទុកឲ្យយុត្តនានិយាយបន្ត៖
«យប់មិញ ពួកម៉ូតូប្រដេញដេញស្ទាក់ខ្ញុំម្តងហើយ!»
«ហើយឯងក៏ចាប់ពួកវាបានដែរ!»រិទ្ធិនិយាយឌឺដង។
យុត្តនាតបធ្វើហី៖
«ត្រូវហើយ! ហើយម៉េចក៏ចម្លើយពួកវាដូចគ្នានឹងពួកនេះដែរ?»
រិទ្ធិនិយាយទាំងហួសចិត្ត៖
«ចម្លើយគេប្រឌិតបានតើ? សំខាន់ហេតុអ្វីគេហ៊ានទទួលធ្វើការ មកឲ្យពួកឯងចាប់បានស្រួលៗម៉េះ?»

ក្នុងពេលយុត្តនាបង្អន់ភាពមានះហើយខាំមាត់ពិចារណាបង្ហាញស្នាម ខួចដ៏ស្រស់សង្ហានៅចុងមាត់ដែលគ្មានស្នាមញញឹម រិទ្ធិក៏ត្រិះរិះក្នួចទុកក្នុងចិត្ត។
អ្នកប្រុសទីពីរដឹងថាលេខាប៉េងមានទាក់ទងក្នុងរឿងនេះ ដូច្នេះចង់មិនចង់ អ្នកនៅពីក្រោយអាចជាឪពុកធម៌គេ ប៉ុន្តែមិនដឹងថាតើគាត់ធ្វើនេះដើម្បីអ្វី?

ទោះគាត់ស្អប់ផ្ទះនោះ ក៏មិនសមថាយកយុត្តនាទៅបុកជាមួយគេដែរ? តែបើថាគាត់មានចេតនាឲ្យយុត្តនាស្អប់ពៅបញ្ញាហាក់ដូចទំនងជាង។

សំឡេងអគ្គទេសាភិបាលហួតស៊ីវលាន់រងំមកវិញហាក់ដូចថ្មីៗ «ប៉េងអ្ហា? កូនប្រុសច្បងខ្ញុំអាចនៅមានមនោសញ្ចេតនាស្នេហាជាមួយក្មេងស្រី ផ្ទះនោះទេដឹងប៉េង?»

រិទ្ធិនឹកឃើញភ្លាមរវើរភ្នែកគិត។ ឬមួយលោកប៉ាធម៌នេះពិតជាមិនទុកចិត្តមនោសញ្ចេតនារវាងកំលោះក្រមុំ ទាំងទ្វេមែន បានជាប្រឌិតរឿងនេះឡើងដល់ទៅជួនៗគ្នាពីរលើក? ទោះយ៉ាងណាគេមិនអាចហាប្រាប់យុត្តនាពីការសង្ស័យក្នុងចិត្តខ្លួនឡើយ។

គេដឹងថា យុត្តនាមានះឆេវឆាវបន្តិចតែគេទៀងត្រង់ណាស់។ គេមានគុណធម៌ហើយស្រលាញ់ឪពុកចិញ្ចឹមស្មើឪពុកបង្កើត។ ការនិយាយប៉ះពាល់ហួតស៊ីវដោយប្រការណាមួយមិនត្រឹមធ្វើឲ្យគេមិនជឿថែមទាំងជះផលអាក្រក់ដល់ខ្លួនវិញផងក៏ ថាបាន ដូច្នេះហើយទើបអ្នកប្រុសទីពីរនិយាយបង្វែរ៖

«ខ្លាចមានអ្នកផ្សេងលេងល្បិចនេះ ហើយឈរឱបដៃមើលឯងនឹងគ្រួសារនោះលេងគ្នា!»

យុត្តនាស្តាប់ហើយនិយាយប្រកែកផ្ទួង៖

«វាគ្មានអ្នកណា! ទំនេរអត់ការធ្វើលេងល្ខោនឆ្កួតៗអស់នេះទេ! អ្នកផ្ទះនោះមានរឿងក្នុងដៃយើង ច្រើនហួស ពិសេសប្អូនពៅគេគឺជំពាក់ខ្ញុំ!»

គេសើចស្ងួតអមកែវភ្នែកដែលអណ្តែតមកនូវវង់ភក្ត្រស្រីតូចពៅបញ្ញា ហាក់កំពុងស្ថិតនៅចំពោះមុខ។ គេនិយាយបន្តទាំងញញឹមល្វីង៖

«គឺគេជំពាក់កិត្តិយសដែលពួកថ្លៃថ្នូរដូចគេចង់ទុកបន្លំភ្នែក មហាជន! បើមិនឲ្យខ្ញុំដេកដី ឬ មួយចូលទ្រុងបាត់ គេនៅវាមិនសុខ!»

«ប៉ែន ពេជ្រប្រាថ្នា កំសាកណាស់ វាមិនហ៊ានប៉ះឯងទេ!»រិទ្ធិនិយាយតប។

យុត្តនាហាក់មានអំនួតនិមិត្តពាក្យនេះ តែគេនិយាយបន្តភ្លាម៖

«វាកំសាក! តែប្អូនវាមិនដូចវាទេ! ប៉ែន ពៅបញ្ញា ហ៊ានឡើង apartment ជាន់ទី៦ជួបមនុស្សប្រុសកណ្តាលយប់អធ្រាត្រ ! ឯងឲ្យតម្លៃអ្នកនាងតូចឯងហួសពេកហើយលោកជំនួយការ»

រិទ្ធិដង្ហើមធំ៖

«សរុបមកវិញ ឯងខឹងនាងឬមួយ....»

យុត្តនាមមីភ្នែកនៅស្ងៀមតែស្នាមញញឹមស្មើៗលើបបូរមាត់គេជាសញ្ញាថា រិទ្ធិកាន់តែនិយាយ គេកាន់ខឹងនារីនោះ។
«កុំខឹងងងឹតងងល់ពេក គេថាខឹងខ្លាំងអាចមកពីស្អប់អាចមកពីស្រលាញ់ តែខឹងមួយណាក៏ដោយ គឺវាខាតតែទាំងអស់!»
«យុត្តនាមិនចេះខាតទេ លោកជំនួយការ! អរគុណដែលបារម្ភ!»
ឃើញគេមានះ រិទ្ធិអស់ពីពន្យល់ក៏ស្ដីឲ្យវ៉ាវះ
«ឯងឈប់ឡប់ទៅយុត្តនា! ពៅបញ្ញាមិនធ្វើអញ្ចឹងទេ!»
គេជាន់ហ្គែបន្ថែមល្បឿនតាមសន្ទុះចិត្តក្ដៅឆួល ពិសេសពេលឮបងប្អូនធម៌កាន់ជើងនាង ហើយថាឲ្យខ្លួនគេកាន់តែចចេសៈ
«ស្រីនោះយល់សប្តិទាំងថ្ងៃហើយដែលគិតថាអាចរួចខ្លួនបានស្រួលៗ!»
រិទ្ធិសើចខឹកៗចំអកចរិតរញ៉េរញ៉ៃរបស់បងធម៌នាយៈ
«អញ្ចឹងឯងប្រុងឲ្យពួកកូនចៅទៅចាប់នាងមកធ្វើទោស?»
«មិនបាច់ភ័យទេជំនួយការ! ក៏មិនបាច់ដាក់អង្គរក្សឃ្វាលដែរ! ស្រីនោះត្រូវមករកខ្ញុំខ្លួនឯង! ចាំមើល គេគ្រាន់ប៉ុណ្ណាជាមួយខ្ញុំ!»
រិទ្ធិនិយាយឌឺទាំងទឹកមុខស្ងប់ៈ
«តែគេក៏មិនអន្ទះសា ចិត្តភ្លើងដូចឯងដែរយុត្តនា!....ឈប់ឡានទៅ ខ្ញុំចុះនៅនេះហើយ!»
យុត្តនាបង្អង់ល្បឿនរួចឈប់ឡាន។ គេងាកមើលមុខរិទ្ធិហើយញាក់ចិញ្ចើមៈ
«គេមិនអន្ទះសា! គេស្ងប់! ដឹងតើ! គេពិសពុលក៏ដឹង! តែសំខាន់គេភ័យ គេខ្លាចពិបាកសងខ្ញុំបានជាខំ....»
រិទ្ធិឈានជើងចុះពីឡាន ជាមួយវាចាស្ងួតស្ងប់ៈ
«គេមិនដែលខ្លាចឯងទេ!....»
យុត្តនារវៃភ្នែកគិតសម្ដីនេះទាំងមុខក្រញូវ។ រិទ្ធិអើតមកបង្ហើយឃ្លារបស់ខ្លួនៈ
«ព្រោះគេដឹងថាឯងនេះ....គ្មានថ្ងៃដាច់ចិត្តធ្វើស្អីគេឡើយ!»
យុត្តនាងើបមុខសម្លឹងរិទ្ធិដោយភ្នែកមូលក្លុំ។ ដល់ពេលអ្នកប្រុសទីពីរញាក់ចិញ្ចើមវិញម្ដងមុនពេលរុញទ្វារបិទ ទៅវិញគ្រាំងហើយញញឹមដើរចេញ។
យុត្តនារវៃភ្នែកចេញទាំងក្នាញ់ហើយចេញឡានទៅវ៉ាវ....

១៣

ទេសាភិបាលថ្មី

ទាំងព្រលឹមអុរ........អ្នកប្រុសធំអគ្គទេសាភិបាលហួតស៊ីវបង្ហាញខ្លួន នៅធនាគារកណ្ដាលរបស់ឪពុកទាំងទឹកមុខមិនសប្បាយចិត្តប៉ុន្មានទេ ព្រោះតាំងពីពេលដែលបែកពីវិទ្ធិមកគេមានចេតនាប្រឡែងលេងជាមួយ ពៅបញ្ញាជម្រះកំហឹង បែរជាខាងនាងខលមិនចូលហើយខាងខ្លួនស្រាប់តែទទួលការហៅទូរសព្ទពី ឪពុកឲ្យមកជួបជាបន្ទាន់។
....តុៗៗ
«ចូលមកចុះ!»
សំឡេងអគ្គទេសាភិបាលហួតស៊ីវតែងតែស្លូតតែងតែថ្លៃថ្នូរជានិច្ចពិសេសគាត់មិនដែលថាគ្មានលេខាប៉េងឈរនៅពីក្រោយខ្នងឡើយ។
«លោកប៉ា!? ពូប៉េង?»
«អង្គុយមកកូន!»
ពេលយុត្តនាអង្គុយហើយ លេខាចំណាស់ធ្វើជាបម្រើផ្កាប់ផ្កុន៖
«អ្នកប្រុសពិសាកាហ្វេឬតែទាន!»
«អត់ទាំងពីរ!»គេឆ្លើយខ្លី ហើយធ្វើព្រងើយនឹងការផ្កាប់ផ្កុននេះធ្វើឲ្យឪពុកគ្រវីក្បាលមួយៗហួសចិត្តចំពោះអាកប្បកិរិយានេះ។ ហួតស៊ីវដៀងភ្នែកឲ្យសញ្ញាលេខាប៉េងក៏ឱនកាយដកថយចេញទៅវិញបាត់ទុក ឲ្យបរិយាកាសមានតែពីរនាក់ឪពុកនិងកូន។

តាមផ្លូវមកកាន់ទីនេះ អ្នកប្រុសធំយល់ថាកម្មវត្ថុក្នុងការហៅជួបនេះប្រហែលអាចជារឿង ស្ដីប្រដៅកុំឲ្យខ្លួនមានគំនុំនឹងកូនប្រុសច្បងផ្ទះប៉ែនពេជ្រ ព្រោះទោះបីអ្នកមិនដឹងថាហួតស៊ីវទទួលបុរសក្មេងនោះជាកូនធម៌ទី បីតាមផ្លូវច្បាប់ក៏ដោយ ប៉ុន្តែគេដឹងថាឪពុកធម៌ខ្លួនមិនចូលចិត្តឪ តែត្រូវជាមួយកូនប្រុសម្ដាយដើមផ្ទះនោះបំផុត។
ពិសេស គឺគេគិតមិនយល់ថា តាមចរិតលក្ខណៈរបស់វិទ្ធិមិនសមទើបនិយាយគ្នាលើឡានប៉ុន្មានម៉ាត់ ក៏យកមកទូលពិតឪពុកខ្លួនឲ្យចេញមុខស្រាយកំហឹងចិត្តជំនួសដែរ។
«ឯងមើលមើល៍កូន! បន្ទប់នេះយ៉ាងម៉េចដែរ?»
យុត្តនាអាល័យតែរវល់ជាមួយភាពសៅហ្មង គេចូលមកមិនបានចាប់អារម្មណ៍ថាបន្ទប់ឪពុកខ្លួនត្រូវបានរចនា ថ្មីយ៉ាងទំនើបបំពាក់ដោយឧបករណ៍ការិយាល័យដ៏សង្ហាគាប់ភ្នែកឡើយ។

ដោយចរិតគេមិនមែនជាមនុស្សឡូយឆាយខាងហ្វេស្ទីនផង គេធ្វើជានិយាយលើកទឹកចិត្តប៉ាធម៌៖
«ស្អាតណាស់!»
គេនិយាយខ្លីៗជាមួយអ្នកផងជាទម្លាប់ទៅហើយ។ នេះគឺយុត្តនាអ្នកប្រុសធំដែលមិនដែលអើតធនាគារនេះសូម្បីកន្លះ ជំហានទេប្រសិនគ្មានការហៅជួប។ គេជាកូនច្បងពិតមែនតែទ្រព្យសម្បត្តិឪពុកជាអ្វីដែលគេមិនដែលយក ចិត្តទុកដាក់ឡើយ។
ទោះយ៉ាងណាហ្គួតស៊ីវដឹងថាកូនច្បងនេះនិយាយតិចតែគេមានគុណធម៌និង អាចទុកចិត្តបាន។ បុរសចំណាស់នេះឆ្លាតប៉ុណ្ណាក៏ស្មានមិនដល់ទេថា លើលោកនេះមានតែមនុស្សម្នាក់ប៉ុណ្ណោះដែលអាចធ្វើឲ្យយុត្តនា និយាយបានច្រើនដូចមនុស្សស្រី នោះគឺមេធាវីសម្បុរស្រអែម«ប៉ែន ពៅបញ្ញា»។
«ចុះពេញចិត្តទេកូន?»
យុត្តនាងើមង៉ាមមិនយល់ថាហេតុអ្វីប៉ាធម៌បែរជាសួរសំណួររបៀបនេះ?។
គេញញឹមស្ទាក់ស្ទើរ៖
«ឲ្យតែប៉ាសប្បាយចិត្ត!»
«តែនេះជាបន្ទប់កូនចាប់ពីពេលនេះហើយ!»គាត់និយាយខ្លីតែច្បាស់ ៗធ្វើឲ្យយុត្តនាបើកភ្នែកមូលក្លុំព្រោះភ្ញាក់ផ្អើល។ រឿងដែលខ្លាចបំផុតក្នុងចិត្តនាយគឺត្រូវគេចងនៅកន្លែងធ្វើការណាមួយ មួយថ្ងៃ៨ម៉ោង ពិសេសគឺនៅធនាគារនេះ។
«ប៉ា???»
«ប៉ាចាស់ហើយ!»

ហ្គួតស៊ីវញញឹមហើយក្រោកដើរមកឈរពីក្រោយកូនប្រុសដែលកំពុងលស់ ព្រលឹង។ គាត់អង្អែលស្មានាយថ្នមៗព្រោះហ្គួតស៊ីវដឹងថាសម្រាប់ ហ្គួត យុត្តនា ការងារនៅទីនេះគឺជាទីឃុំឃាំងសម្រាប់គេ។
«ប៉ាត្រូវការអគ្គនាយកថ្មីរបស់ធនាគារនេះ!»
ដោយភ័យផ្អែមមាត់យុត្តនានិយាយតបវិញមិនឲ្យគាត់បញ្ចប់បានឡើយ៖
«លោកប៉ា! ខ្ញុំមិនចេះទេ! ខ្ញុំធ្វើមិនបានទេ! ឲ្យរិទ្ធិធ្វើទៅ?»
ហ្គួតស៊ីវសើច ព្រោះគាត់ដឹងហើយថាគេនឹងឆ្លើយរបៀបនេះ។

«កូនប្រុសធំខ្ញុំជាមនុស្សត្រូវជាមួយការងារនេះជាងគេ! កុំចង្អុលអ្នកផ្សេងបើប៉ាចង្អុលកូន!»
«តែខ្ញុំ....ខ្ញុំមិនចេះ តើធ្វើម៉េចបានទៅ?»
ហួតស៊ីវសើចតិចៗ៖
«ចាប់ផ្តើមសាកខ្លួនឯងទៅ! ចំណែកមនុស្សពូកែៗក្នុងប្រទេសនេះ ចាំប៉ាហៅឲ្យមកតម្រង់ជួរឲ្យកូនប្រើ! កូនប្រុស»
«ហួត ស៊ីវថាអ្នកណាធ្វើបានគឺអ្នកនោះហើយកូន!»
គេរកហាមាត់បន្តតែគេឈប់វិញ។
អ្នកប្រុសធំដឹងហើយថា វាអត់ប្រយោជន៍ទេក្នុងការតវ៉ាជាមួយអ្វី ដែលឪពុកធម៌បានសម្រេចចិត្តរួចទៅហើយនោះ។ គេនៅផ្អែកខ្នងទាំងខ្វល់ខ្វាយ តែកង្វល់នោះមិនបានបិទបាំងភាពស្រស់សង្ហានិងរហ័សរហួនរបស់គេឡើយ។ ប្រការនេះធ្វើឲ្យហួតស៊ីវញញឹម នឹកឃើញដល់រឿងថ្មី។ គាត់ស្រដីតិចៗពីក្រោយខ្នងកូនប្រុស៖
«មនុស្សប្រុសពេលនៅកំលោះធ្វើយ៉ាងណាក៏បាន តែពេលកសាងគ្រួសារហើយចាំបាច់ត្រូវមានឋានៈមួយ!...»
យុត្តនារភ្ញែក រិះគិតដោយពិភាល់សាជាថ្មី។
លោកប៉ាធម៌ឈរបែរខ្នងសម្លឹងទៅទេសភាពខាងក្រៅបង្អួចកញ្ចក់ធំច្រងាង តែគាត់ដឹងថាកូនច្បងកំពុងមានអារម្មណ៍ក្រឡាប់ចាក់។ បន្លាយពេលពង្វាងវែងឆ្ងាយមិនមែនជាចរិតលក្ខណៈរបស់ ហួត ស៊ីវ ឡើយ៖
«ប៉ាបានទៅដណ្តឹងកូនស្រីជំទាវកុសុមាជាកូនប្រសាស្រីច្បងរបស់ប៉ា!»
ដូចគេជះទឹកមួយចាំងកណ្តាលមុខ យុត្តនាស្ទុះក្រោកពីកៅអីបែរខ្នងមករក ហួត ស៊ីវ។ បុរសចំណាស់បែរក្រោយសន្សឹមៗសម្លឹងមុខកូនប្រុសទាំងញញឹមស្ងួតស្ងប់។
«កូនស្រីប៉ែនពេជ្រ?.....»
គេមិនរង់ចាំចម្លើយទាន់ទេ គេប្រកែកដោយសម្លឹងមុខឪពុកយ៉ាងមុត៖
«ទេ! លោកប៉ា!»

ហួត ស៊ីវដើរសន្សឹមៗមកប្រឈមនឹងកូនច្បង។ គាត់និយាយតិចៗ៖
«ប៉ែន ពេជ្រអមរា!»
ក្រមុំអភិជនជាអនាគត CEO អាជីវកម្មកែសម្ផស្ស ដែលខ្លួនបានបើកឡានទៅបុកទង្គិចលេង

កាលពីពេលថ្មីៗនេះលេចឡើង ក្នុងអារម្មណ៍នាយ។ យុត្តនាទទួលអារម្មណ៍ថាចត់សូម្បីទឹកមាត់។

«មួយណាក៏ដោយ! ឲ្យតែកូនស្រីផ្ទះនោះគឺមិនបាន!»

យុត្តនានិយាយដោយម៉ឺងម៉ាត់ហើយងាកមុខគេចចេញពីភ្នែកឪពុកធម៌។

សំឡេងគាត់លាន់មកវិញមួយៗ៖

«ជាកូនវាតែជាកូនដែលត្រូវវាបោះបង់ចោល ហើយទៅសោយសុខប្រពន្ធថ្មី! ក្មេងស្រីនោះមានអីខុស? គ្នាមិនដឹងអីទេ!»

«ប៉ែន ពេជ្រប្រាថ្នា ទើបតែចាត់មនុស្សមកធ្វើបាបខ្ញុំ! គេចង់ឲ្យខ្ញុំជាប់គុក!»

«ឯងខុសហើយកូន! ក្មេងនោះមិនហ៊ានលេងជាមួយឯងតាំងពីដើមមកម្ល៉េះកូន! រឿងហេតុប៉ាដឹង!!!ប៉ាឲ្យគេទៅស៊ើបអស់ហើយ!»

យុត្តនាងាកមកវិញយ៉ាងរហ័ស។

បុរសនេះជាមនុស្សដែលអ្នកជឿជាងគេក្នុងជីវិតនេះ។ ពេលនេះគាត់បង្វែបចម្លើយអ្នកប្រាកដជាត្រងត្រាប់ស្តាប់ដោយភ្លេច គិតរឿងរំខានផងទាំងពួង៖

«កូនប្រពន្ធចុងវារៀបចំអន្ទាក់យប់មិញនេះ! អត់ទាក់ទងនឹងផ្ទះកុសុមា! តែពេលកូនសួរទៅវាឆ្លើយដាក់ក្នួយប្រាថ្នាឲ្យបានរួចខ្លួន!»

យុត្តនាសម្លឹងមុខឪពុកយ៉ាងមុត តែអារម្មណ៍គេមិននៅទីនេះពេញលេញទេ។ ទឹកមុខគេធ្វើឲ្យហួតស៊ីវបានឱកាសចាក់ដោតបន្ថែម៖

«មនុស្សស្រីណាកូន! កាន់តែត្រជាក់កាន់តែជ្រៅ! បើឃើញគេកាន់តែនឹងនកូនឯងត្រូវតែប្រយ័ត្ន! ស្រីនោះដើម្បីលាក់ការជួយផ្លូវចិត្តឪពុកគេហើយសងសឹកបងប្រុសធំគេ គេប្រើព្រួញមួយបាញ់សត្វពីរ ទីមួយបំផ្លាញកូនឯង បើបានសម្រេច កូនឯងគ្មានឱកាសនិយាយទេ តែបើមិនបានសម្រេច គេទម្លាក់ទៅបងប្រុសគេ ទុកឲ្យកូនឯងប្រខាំគ្នា!»

យុត្តនារវេភ្នែកគិត....

លោកឪពុកដើរមកកាន់តែកៀក....សំឡេងគាត់លាន់មកបន្ត៖

«អ្នកណាមិត្តអ្នកសត្រូវចែកឲ្យដាច់! ជួនកាលយើងមនុស្សប្រុសយើងនៅសល់ចិត្តខ្លះ តែស្រីៗគឺចិត្តដាច់ណាស់! កូនប្រុសប៉ាចិត្តទន់យ៉ាងនេះលោតែចាញ់បញ្ឆោតគេ គេចាប់ដាក់ខ្នោះឃ្នាងបាត់គេអ្នកចេះច្បាប់ចេះអីច្រើនផង ប៉ាឯណេះចាស់ហើយ ខំចិញ្ចឹមកូនសង្ឃឹមកូនបាន

ជួយជំនួសដៃជើង ទៅរងគ្រោះដោយសារស្រី វាគួរឲ្យតូចចិត្តដែរណ៎ាកូន!»
សម្ដីគាត់មានន័យជ្រៅ បើមិនដៀមដាមថានាយល្ងង់ចាញ់មនោសញ្ចេតនាខ្លួនឯងជាមួយស្រីមេធាវី នោះក៏ហាក់ដូចមានន័យថាគាត់ខំចិញ្ចឹមច្រើនឆ្នាំក៏អត់ប្រយោជន៍ សោះ។
យុត្តនាកាន់តែហ៊ុមព័ទ្ធសន្ទប់ដោយអារម្មណ៍សៅហ្មង។ គេនៅស្ងៀមតែជាធម្មតាការសង្ស័យថាពៅបញ្ញាក្បត់គេក៏កាន់តែរីក ធំឡើង។
ជាមួយស្រីម្នាក់ដែលគេនៅចងចាំនាងក្នុងបេះដូង តែបានបែកគ្នាជាច្រើនឆ្នាំព្រមទាំងមានឪពុកជាសត្រូវទៀតផ្ញើ ម៉េចឲ្យយុត្តនាជឿជាក់ស្មើនឹងឪពុកធម៌ដែលជាអ្នកស្រោចស្រង់នាយតាំងពីកាលៈទេសៈលំបាកបំផុតនោះ។
អ្នកកាត់ចិត្តដកដង្ហើមយូរហើយនិយាយមួយៗ៖
«លោកប៉ាប្រើកូនធ្វើអ្វី រៀបការនឹងអ្នកណាកូនធ្វើតាមទាំងអស់!»
គេងើបមុខសម្លឹងបុរសចិនដែលញញឹមផ្អែមចំពោះមុខ។ អ្នកប្រុសបញ្ចប់ប្រយោគរបស់ខ្លួន៖
«បើប៉ាថាអ្នកណាត្រូវ គឺអ្នកនោះត្រូវហើយ!»
ហ្វួតស៊ីវមើលឃើញកំហឹងនិងការសងសឹកលាក់ក្នុងពន្លឺភ្នែកបុរសក្មេង នេះ។ ឪពុកធម្មតាគឺមិនសប្បាយចិត្តទេដែលកូនលាក់ភ្លើងមួយដុំក្នុង បេះដូង តែហ្វួតស៊ីវគឺចង់បានឲ្យយុត្តនាក្លាយជាបែបនេះហើយ។ គេស្លុយហើយមិនចេះទុកមុខអ្នកណាទេ អ្វីដែលអ្នកផងមិនហ៊ានធ្វើ អ្វីដែលអ្នកប្រុសទីពីរ ហ្វួត ខេមរិទ្ធិ មិនធ្វើ គឺអ្នកប្រុសច្បងធ្វើ ។
ហ្វួតស៊ីវដឹងថាក្រឡាអុករបស់គាត់ជោគជ័យតាំងពី១០ឆ្នាំដែលក្មេង ប្រុសនេះចូលមកក្នុងជីវិតគាត់ហើយប្រើត្រកូលរបស់គាត់។
«កូនច្បងរបស់ប៉ា! ប៉ាដឹងថាឯងកតញ្ញូ! Enjoy the Views អគ្គទេសាភិបាល ហ្វួត យុត្តនា!»
ថាហើយគាត់ទះស្មានាយថ្នមៗមុនពេលចាកចេញពីបន្ទប់ ទុកឲ្យអ្នកលេងមុខស្រស់នៅឈរទ្រឹងម្នាក់ឯងបែរមុខទៅរកបង្អួច កញ្ចក់ធំល្វឹងដែលសឹងថាអាចសម្លឹងទៅឃើញទីក្រុងភ្នំពេញទាំងមូល បាន។

«ពៅបញ្ញា....ស្រីមានល្បិច!»
គេរអ៊ូតិចៗក្នុងបេះដូង....មុនពេលលើកទូរសព្ទមកចុច.....។
នៅខាងណោះទោះខំលើករួសរាន់យ៉ាងណាក៏នៅមិនស្មើនឹងសន្ទុះចិត្តរបស់បុរសនេះដែរ។ គេវាចាមួយៗដោយទឹកមុខស្មើ៖

«ស៊ើបដឹងរឿងឬនៅ?»
សំឡេងពីចុងម្ខាងឆ្លើយតប៖
«ពៅបញ្ញាចេញទៅអាមេរិកហើយបង! តែស៊ើបសួរដឹងថាសំបុត្រយន្តហោះទិញសម្រាប់តែបួនថ្ងៃទេ!»
យុត្តនានិយាយតបវិញខ្លី៖
«អរគុណ!»
គេចុចបិទ....
អគ្គទេសាភិបាលមិនទាន់គ្រងឯកសណ្ឋានអាជីពនិងមិនទាំងស្គាល់ការងារ ខ្លួនថាត្រូវធ្វើអ្វីបែរជាមិនខ្វល់ខ្វាយត្រេកត្រអាលចំពោះការងារថ្មីអ្វីបន្តិច តែគេមមីភ្នែកមើលស្រមោលខ្លួនឯងក្នុងកញ្ចក់។ គេប្រាប់ខ្លួនឯងដោយមិនហើបមាត់៖
«៤ថ្ងៃ???? ខ្ញុំចាំនាងបានជានិច្ចពៅបញ្ញា!»

១៤

«ដើមសារិកាកែវ»

...ពន្លឺ Flash រេរាំយ៉ាងស៊ីវិល័យលើស្បែកទន់រលោងពណ៌ទឹកឃ្មុំរបស់នាង វាហាក់មិនមែនជារឿងប្លែកទេសម្រាប់រវាងពេលបីឆ្នាំចុងក្រោយដែល បុស្បាបានក្លាយជា Super Model។
«អ្នកនាងបុស្បា! យប់មិញម៉ោង១ជាងមានគេឃើញនាងចេញពីក្លឹបជាមួយប្រុសអ្នកមានម្នាក់ជិះ ឡានពណ៌ខ្មៅមានអង្គរក្សជិះប្រដេញតាមពីក្រោយការពារគេ នោះជាអ្នកណាទៅ? ជាសង្សារមែនទេ?»
ស្រីស្អាតបង្រួមបបូរមាត់ក្រហមទុំ រកកលបញ្ឈប់ស្នាមញញឹមនៅចំពោះមុខកាណុងកាមេរ៉ារាប់សិបដែលបាញ់មក ព្រោះប្រយោគសំណួរនេះហាក់អសុរោះពេកសម្រាប់អ្នកស្រលាញ់កេរ្តិ៍ឈ្មោះ ដូចនាង។
ជំនួយការនាងលាន់មាត់មកចប្រែចតជំនួសភ្លាម៖
«កុំនិយាយផ្ដាស! អ្នកនិយាយហ្នឹងច្រឡំមនុស្សហើយ! អ្នកនាងបុស្បាមិនដែលចេញទៅលេងក្លឹបអីទេ! នាងរកតែពេលគេងមិនបានផង! យប់មិញនៅថតឲ្យខាងទឹកអប់រហូតដល់ម៉ោង១យប់ហើយក៏ទៅផ្ទះ! call ទៅសួរខាង studio ទៅបើចង់ច្បាស់!»
...នៅចម្ងាយប៉ុន្មានម៉ែត្រពីទីដែលបុប្ផាត្រូវបានចោមរោម....បុរសៗ នាំគ្នាងាកទៅរកកញ្ញា

Super Model តាមចន្លោះសេសសល់ពីក្រុមសារព័ត៌មាន។ ពួកគេក៏ជាកន្លង់មកពីមជ្ឈដ្ឋានមានមុខមានអំណាចពុំនោះទេគឺ អ្នកមានប្រាក់ដែលជាលក្ខខណ្ឌនៃកម្មវិធីយប់នេះ។
«អគ្គទេសាភិបាលថ្មីក៏ចាញ់សម្រស់នាងដែរ?»
សំឡេងពាណិជ្ជករវ័យក្មេងម្នាក់ ដែលទើបតែទាក់ទងមកធ្វើស្និទ្ធស្នាលនឹងយុត្តនាបន្ទាប់ពីគេជា អ្នកសម្រេចចិត្តធំបង្អស់នៃធនាគារកណ្ដាលរបស់ហួតស៊ីវនិយាយឌឺ ដងមកឲ្យនរៈសង្កាក្នុងចេតនាថាប្រសិនគេពេញចិត្តនាងមែន ខ្លួននឹងអាលរកឱកាសឲ្យដើម្បីជាគ្រឿងលួងចិត្ត។ តែយុត្តនាមិនចុះចាញ់ការឌឺដងនេះ នាយញញឹមសម្លឹងមុខធុរកិច្ចជនដែលជាម្ចាស់វាចាហើយតបៈ
«នាងស្អាតណាស់ អ្នកណាឃើញក៏មើលដែរ កុំថាតែខ្ញុំ!»
«បុស្បានារី!...ឈ្មោះរបស់គេ!»ធុរកិច្ចជនវ័យក្មេងម្នាក់ទៀតលូកមាត់។
យុត្តនាងាកទៅរកទីនោះម្ដងទៀតតាមនិស្ស័យភូមរាដែលជានិច្ចកាលទាក់ទាញដោយលំអងផ្កាស្រស់។
ក្រុមអ្នកសារព័ត៌មានបែកខ្ញែកគ្នាបន្តិចហើយដោយសារ Super Model ឈានហួសគេចទៅផុតពីព្រំក្រហមដោយសារតែសំណួរយ៉ាប់ៗរបស់ពួកគេ តែក្រសែភ្នែកទេសាភិបាលថ្មីហួតយុត្តនានៅរក្សានៅទីនោះដដែល ព្រោះនាយត្រូវទាក់ភ្នែកនឹងការបង្ហាញខ្លួនរបស់នារីផ្សេងម្នាក់ ទៀត ....
....នាងគ្រងឈុតពណ៌លឿងស្រាល មិនបុរាណក៏មិនទំនើបហួស តែនាងពិតជាមិនគួរឲ្យជឿថាជាបុត្រីពៅរបស់ឧកញ៉ាប៉ែនពេជ្រនោះ ដែរ បើកុំតែសំឡេងខ្សឹបខ្សៀវលាន់មករសឹបៗក្បែរអ្នកកំលោះយើង....
«មេធាវីពៅបញ្ញា?»
ពួកពាណិជ្ជករវ័យក្មេងដែលនៅចោមរោមអគ្គនាយកធនាគារថ្មីលាន់មាត់ សួរគ្នាក្នុងពេលអ្នកសារព័ត៌មានបែរទិសដៅរត់ត្របាញ់មករកនារី អ្នកច្បាប់ ដែលទើបតែប្រឈមនឹងរឿងដ៏រសើបរបស់ឪពុកខ្លួន។
«នាងឡូយម្ល៉ឹងៗបានជាកាសែតតាមថតមើលតែពួកតារា!»
សំឡេងរបស់ពួកគេទង្គិចចិត្តយុត្តនាឲ្យផុសក្ដីសៅហ្មងឡើងមិន ច្បាស់ថាច្រណែនមិនច្បាស់ថាប្រចណ្ឌហើយក៏មិនច្បាស់ថាខឹងស្អប់ តែច្បាស់ណាស់ គេមិនអាចដកភ្នែកចេញពីនាងបានឡើយរហូតដល់បញ្ញាខ្លួនឯងដោយលើក កែវស្រាក្រហមលើដៃមកក្រេបបន្តប់......។

ស្ត្រីសម្បុរស្រអែមដែលកម្រប៉ះក្រែមម្សៅពេលត្រូវនឹងភាពរោលរាល របស់រស្មីភ្លើងពណ៌មាសនិងឈុតរាត្រីសមោសរទន់ល្មៃ ហេតុអ្វីនាងអាចក្លាយជាទេពអប្សរតូចបានយ៉ាងងាយជាមួយស្នាមញញឹម គួរសម?
ដែលគួរឲ្យស្ដាយគឺស្នាមញញឹមនោះឆាប់ចប់ពេក ដោយសារតែនាងបែរកាយមកទាក់ភ្នែកនឹងរូបរាងខ្ពស់សង្ហា របស់ទេសាភិបាលក្មេង ក្នុងចំណោមបុរសៗពាណិជ្ជករមួយក្រុមនៅចំពោះមុខនាង។
ពៅបញ្ញាផ្អាកអារម្មណ៍ល្អធូរស្រាលក្នុងអង្គពិធី ប៉ុន្តែប្ដូរមកវិញនូវពិភាល់មិនស្រួលចិត្ត....
ដែលសំខាន់គឺបុរសនោះ សម្លឹងមកនាងដោយក្រសែភ្នែកចម្លែក និងគ្មានស្នាមញញឹមលើបបូរមាត់។
កែវស្រាលើដៃគេនៅនឹងថ្កល់ស្មើនឹងទឹកមុខសោះអង្គើយរបស់គេ ដែលសម្លឹងមកនាងធ្វើឲ្យស្រីបែរជាជ្រួលច្រាលក្ដុកក្ដាក់ ក្នុងចិត្ត។
«ម៉េចក៏មកជួបគេទៅកើត? ហើយគេកើតអីបានជាមើលមកយើងរបៀបនេះ?»
ធីតាដកភ្នែកចេញវិញ សន្សឹមៗបម្រុងបែរខ្លួនចេញទៅទិសផ្សេងទោះបីដឹងថាបុរសនោះមិនទាន់ដកក្រសែភ្នែកសោះកក្រោះនោះទៅវិញក៏ដោយ។ សំឡេងពួកអភិជនកំលោះៗលាន់មករំខានអារម្មណ៍អ្នកប្រុសធំដែលឈរ ស្ងៀម ...
«គួរតែរកឱកាសចាប់ដៃអ្នកនាងធំផ្ទះប៉ែនពេជ្របានម្ដង!»
«នាងជាកូនពៅទេហៅអ្នកនាងតូចត្រូវជាង!?»
«នាងមានអំណាចជាងគេនៅផ្ទះប៉ែនពេជ្រ ហៅអ្នកនាងធំទើបត្រូវ!»
«ក្រែង ប៉ែន ពេជ្រប្រាថ្នា មានលុយច្រើនជាងគេក្នុងចំណោមកូនៗទាំងបួនរបស់ឧកញ៉ានោះ?»
«បីអ្នកនោះកូនដើមទេ! ម្នាក់នេះជាកូនម្ដាយក្រោយ! ដែលនៅគ្រប់គ្រងផ្ទះប៉ែនពេជ្រសព្វថ្ងៃ! នាងជាសំណព្វចិត្តរបស់ឧកញ៉ាឪពុកនាង»
«អត់ខ្វល់! សំខាន់គឺស្អាតអីស្អាតយ៉ាងនេះ?»
មនុស្សស្រីដែលកំពុងមានវត្តមានក្នុងអារម្មណ៍ខ្លួនហើយធ្វើឲ្យ ខ្លួនកើតចិត្តសៅហ្មងមិនទាន់រំលត់ត្រជាក់បាន បែរជានៅសុខៗបាត់ខ្លួនហើយលេចមុខមកវិញកណ្ដាលចំណោមកន្លង់នានាជា មួយរូបសម្ផស្សកាឡាដូចទេវតាស្រីធ្វើម៉េចអាចឲ្យអគ្គទេសាភិបាល ថ្មីទប់ចិត្តមិនធ្វើអ្វីនាងនោះ។

គេថយចេញពីក្រុមធុរកិច្ចជនតាំងពីពេលណាមិនដឹងតែលេខទូរសព្ទ គេបានអណ្តែតមកលើអេក្រង់ Smart Phone នាងទៅហើយមិនខ្វល់ថានាងកំពុងស្ថិតនៅក្នុងចំណោមមិត្តនារីៗឡើយ។
ស្រីក្រមុំដែលរឹងប៉ឹងជានិច្ចលើសវនាការបែរជាពិបាកចិត្តណាស់ពេល ឃើញលេខគេ នាងរេភ្នែករកមើលគេមិនឃើញនៅទីតាំងដើមឡើយ ។

ស្រីតូចដើរឃឹតៗលើកម្រាលព្រំចាកចេញពីចំណោមអភិជនស្រីៗ ទើបបានចុចទទួល។ មិនទាន់បានហាមាត់ថាយ៉ាងណាផង អ្នកប្រុសដែលប្រើទឹកមុខសោះកក្រោះស្វាគមន៍នាងអំបាញ់មិញបង្ហើរមកមុនទៅហើយ៖
«call រកអ្នកនាងធំមិនស្រួលប៉ុន្មានមែន!?»
គេនៅតែឱដងនិងបញ្ចិតបញ្ចៀងជានិច្ចក្នុងឃ្លាសន្ទនានិមួយៗ។ ស្រីស្អាតមិនដឹងត្រូវតបយ៉ាងណា ថាយ៉ាងណាឡើយសម្រាប់ភាពគ្មានហេតុផលនេះ នាងនៅស្ងៀមដូចទុកឱកាសឲ្យខ្លួនឯងបានដកដង្ហើមបន្ធូរភាព តឹងទ្រូង តែអ្នកប្រុសធំដូចជាមិនចង់ឲ្យនាងដកដង្ហើមស្រួលទេ គេនិយាយមកទៀតភ្លាម៖
«៥នាទី!!! ខ្ញុំចាំនាងនៅខាងក្រោម! នៅកន្លែងចតឡាន! ចំណត A1»
ភ្ញាក់ចេញពីភាពស្មុគស្មាញតែទៅជាភាន់ភាំង នាងសួរដោយព្រាងទុក៖
«ហេតុអី?»
«នាងគ្មានសិទ្ធិសួរទេមេធាវី! »
«លោក??????»
«ទ្រនិចនាឡិកាដើរលឿនណាស់ ខ្ញុំចាប់រាប់ហើយ!! បើនាងឃឹតតែមួយវិនាទី នាងកុំបន្ទោសខ្ញុំ!»
«លោកមានសិទ្ធិអីមកគំរាមខ្ញុំ!!»នាងសួរទាំងខឹងញ័រមាត់តែសំណើច នាយពីចុងម្ខាងស្រាលៗធ្វើឲ្យនាងនឹកឃើញដល់ Apartment ជាន់ទី៦កាលពីថ្មីៗនេះ។ ភាពស្មុគស្មាញខ្វល់ខ្វាយកើតឡើងក្នុងពន្លឺភ្នែកស្រីតូច។
«យុត្តិនា! ខ្ញុំទៅហើយ....! តែ....ខ្ញុំអត់ទាន់ដឹងថាលោកនៅឯណាទេ!»
នាងនិយាយតិចៗទាំងយកដៃខ្ទប់ទូរសព្ទ ព្រោះមិនចង់ឲ្យអ្នកផងឮ។
«សង្ឃឹមថាអត់ឃឹតទេណ៎ា!»

អ្នកប្រុសបិទទូរសព្ទមិនចង់ឮពាក្យតវ៉ារបស់នាងហើយគេញញឹម ម្នាក់ឯងក្នុងរថយន្តដែលបញ្ឈរវង់ចាំរួចស្រេចក្បែរច្រកចេញនាទីផ្លា ចំណតរថយន្ត ដែលប្រាកដថានាងមកដល់ក៏អាចឃើញគេភ្លាម។

ស្រីតូចដែលយោងកាយលើស្បែកជើងកែងតូចខ្ពស់ និងសំពត់រាត្រីសមោសរវែងអូសដីចាកចេញពីពិធីក្រោមភាពសោកស្ដាយរបស់ កន្លង់នានា។

នាងឈររេរាដោយទឹកមុខបារម្ភដោយមិនដឹងទេថាទេសាភិបាលហក់លោតកំពុងអង្គុយកាន់ចង្កូតឡានសម្លឹងមកនាងជាការកម្សាន្ត។

នាងងាកមកក៏ឃើញគេមែន ព្រោះគេមិនមែនចង់លាក់ខ្លួនពួននាងឯណា។

ធីតាពៅបញ្ញាដកដង្ហើមយូរ រួចឈានជើងតម្រង់ទៅ ។ មួយជំហានមួយជំហាននាងភ័យជានិច្ចថា បុរសនេះនឹងមិនដែលនាំរឿងល្អមកឲ្យនាងឡើយ។ ទោះនាងខំប្រឹងពន្យារពេលយ៉ាងណា ដើរយឺតយ៉ាងណានាងនៅតែទៅដល់ទីនោះ...

យុគ្គនាញញឹម ហើយធ្វើដៃជាសញ្ញាឲ្យនាងចូលមកក្នុងឡានដោយខ្លួនឯង។

គ្មានពេលណាមួយក្នុងជីវិត ដែលពៅបញ្ញាឈានឡើងជិះរថយន្តអ្នកណាម្នាក់ហើយគ្មានគេចាំបើកទ្វារជូននាងនោះឡើយ។

ភាពក្រអឺតក្រទមរបស់អ្នកប្រុសធនាគារធ្វើឲ្យស្រីអ្នកច្បាប់កាន់តែឆ្អែតចិត្ត។

នាងដើរមួយៗ សំដៅទៅរកនាយទាំងស្រពោន។ ទីបំផុតគេក៏មិនឈ្លើយដាក់ទងបុប្ផាពេកដែរ ។

នាយឈោងដៃមករុញទ្វារឲ្យអមដោយជាស្រេចនូវស្នាមញញឹម។

«ទៅណា?»នាងសួរជាលេសដំអក់នៅក្រៅទ្វារ។

ស្នាមញញឹមគេជ្រុះធ្លាក់ដល់ដីជំនួស មកវិញនូវក្រសែភ្នែកស្មើធេងលែងសម្លឹងនាង។ សម្ដីគេនៅតែជាយុគ្គនាដែលគំរោះគំរើយគ្មានក្រែងចិត្តចំពោះនាទី ទ្រង់គ្រឿងឡើយៈ

«ចង់នៅឲ្យពួកប្រុសៗតាមសុំរលាក់ដៃម៉េស? ចូលចិត្តអញ្ចឹង?»

ស្រីស្អាតរភ្នែកចេញទាំងសៅហ្មង។

គ្មានអ្នកនាងនៃគ្រួសារអភិជនណាមួយដែលអាចទម្លាប់បាននឹង ពាក្យអសុរោះអស់នេះទេ តែពៅបញ្ញាប្រាកដជាគ្មានជម្រើសហើយបានជានាងសង្កត់ចិត្តឈានឡើងឡាន គេទាំងចិត្តទោមនស្សរកទីបំផុតគ្មាន។

ស្រីស្អាតទើបតែអង្គុយដល់ពូកយោងជើងទាំងគូឡើងរថមិនទាន់បាន ស្រួលបួលផង នាយ
បត់ចង្កូតចេញឡានរឹងធ្វើឲ្យនារីទប់កាយស្ទើរមិនជាប់របូត ធ្លាក់ស្បែកជើងកែងមួយចំហៀង
ខាងស្តាំនៅទីនោះហើយស្រទ្បាំងកាំង។
គេឈប់ឡានវិញងឹតធ្វើឲ្យដើមទ្រូងស្រីស្អាតស្ទើរប៉ះទង្គិចនិង តួរថយន្តខាងមុខនាង….. នាង
ច្បាស់ជាច្រឡំហើយដែលគិតថាគេប្រហែលឈប់ឡានឲ្យនាងរើស ស្បែកជើងព្រោះថាគេ
គ្រាន់តែឱនមកទាញទ្វារបិទឲ្យនាងវិញគ្រាំង តែប៉ុណ្ណោះ។
ម្តងណេះអ្នកប្រុសទីមួយចេញឡានរឹងលែងមើលក្រោយធ្វើឲ្យនាងសម្លឹងគេដោយខឹងចិត្ត
ស្ទើរស្រក់ឈាមជំនួសទឹកភ្នែក។
គេញញឹមម្នាក់ឯងហើយទើបងាកមកប្រឈមនឹងនាង។
ក្រសែភ្នែកមុតថ្លារបស់ពៅបញ្ញាដែលសម្លឹងមុខនាយថ្មែធ្វើឲ្យនាយ កាន់តែសប្បាយចិត្តព្រោះ
គេបានធ្វើឲ្យនាងខឹងពេញបន្ទុក ចំណែកសញ្ញាពេលខឹងរបស់នាងគឺសម្លឹងមុខគេដូចគ្រូ
សម្លឹងសិស្ស។
«ម៉េច? មិនល្អ? បានទុកស្បែកជើងម្ខាងដូច Cinderella ហើយ! គង់តែមានព្រះអង្គម្ចាស់
តាមរកដល់ផ្ទះទេ! »
នាងកាន់តែខឹងមុខកាន់តែស្លេក នាងមិននិយាយព្រោះមិនចេះភាសាឌឺដងផ្លែផ្កាដូចនាយ តែ
ចិត្តនាងគឺដូចភ្លើង១០០អង្សាទោះរំងាប់យ៉ាងណាក្តី។
….មេធាវីកំព្រាម្តាយ ដែលស្គាយការអត់ធ្មត់លើសពីអ្នកផងខំទប់ណាស់ មិនឲ្យកំហឹងនាង
រចនាជាទឹកភ្នែកកំដរការសប្បាយនៃបុរសនេះទេ។ នាងសង្កត់ចិត្តហើយសង្កត់ចិត្តទៀត
ដើម្បីឲ្យសូរសម្លេងនាងនៅតែមាំទាំនឹងនះ
«ចង់យ៉ាងម៉េចក៏ឆាប់និយាយទៅ?»

គេនិយាយផ្ទូង៖

«អត់និយាយ! គឺធ្វើតែម្តង!»
ស្មានមិនដល់គេឱនមករឹងតម្រង់មុខនាងធ្វើឲ្យនាងតក់ក្រហល់ងាកចេញ៖
«មនុស្សរោគចិត្ត!»
នាងគិតទាំងទោសៈតែក៏មិនដាច់ចិត្តនិយាយចេញមកឲ្យឮដល់ត្រចៀកគេ ដែរ ក្នុងពេលភាគី
បុរសញញឹមផ្អើននឹងវិនាទីសៅហ្មងរបស់នាង។

.....ទិដ្ឋភាពរាត្រីកាលនៅរាជធានីភ្នំពេញរត់ថយក្រោយតាមល្បឿន រថយន្តរបស់ទេសាភិបាលថ្មីដែលដឹកស្រីស្អាតចាកចេញពីពិធីលំដាប់ អភិជន។ គេដោះអាវធំក្រាស់ឃ្មឹកនោះចេញព្រោះមិនទម្លាប់ហើយក៏បោះចោល កិរិយាជាអ្នកធំនៅក្នុងពិធីនោះ មកហួចលេងកំដរភាពសៅហ្មងរបស់ភ្ញៀវតូច។

ស្រីស្អាតក្នុងសំពត់សូត្រ តែរបូតបាត់ស្បែកជើងមួយចំហៀង ដៃក្តាប់ទូរសព្ទយ៉ាងណែនហើយអើតសម្លឹងសងខាងផ្លូវទាំងបារម្ភ។ ប្រការដែលសំខាន់គឺឲ្យតែគេមិនបើកឡានចេញពីក្រុងគឺជារឿង ល្អសម្រាប់នាងក្នុងកាលៈទេសៈនេះ។

...ដំបូងនាងងងឹតមុខរហូតមិនខ្វល់ថាទៅណា តែចុងក្រោយនាងទើបតែដឹងថាជំនិះបានឈប់នៅទីតាំងមួយដែលនាង ធ្លាប់ស្គាល់ តែខានមកជាយូរមកហើយ។

នាងនៅអង្គុយស្ងៀមទ្រឹង ព្រោះនឹកឃើញឡើងវិញនូវក្លិនផ្កាសារិកាកែវដ៏ក្រអូប ដែលនាងធ្លាប់ចំណាំបាននៅលើផ្ទះតូចខ្ពស់ងាយសម្លឹងឃើញលំហមេឃ ហើយដែលពេលលោកប៉ានាងនាំមកលេងពេលណាចាស់ៗនិយាយគ្នាខាងក្នុង ក្មេងៗលេងបេះផ្កាខាងក្រៅ។

....យុត្តនាឈានចេញចោលជំនិះដោយរុញទ្វារបិទវិញគ្រាំងដូច ពញ្ញាក់ពៅបញ្ញាឲ្យស្វាងចេញពីភាពស្រមើស្រមៃ។

នាងដឹងខ្លួនស្វាងអារម្មណ៍មកវិញក៏ឃើញវត្តមានគេឈរក្បែរកៅអី នាងទៅហើយ គឺគេដៃម្ខាងកាន់ទ្វារឡាន ដៃម្ខាងច្រត់ចង្កេះ ហើយសម្លឹងមកជើងនាងទាំងញញឹមបញ្ឈឺ។

«ត្រូវការឲ្យបីចុះទេ?»

មេធាវីឈ្មោកដោះស្បែកជើងដែលនៅសល់ម្ខាងជាកិច្ចបង្ហើយបង្ហាញថា នាងនឹងដើរដោយជើងទទេហើយដៃស្តាំស្រីស្អាតវាសរុញបុរសនោះចេញពី ច្រកទ្វារ។

ទម្លាប់លែងនិយាយអ្វីទាំងអស់ក្នុងពេលខឹង គឺជាទម្លាប់របស់ពៅបញ្ញា។

នាងយោងសំពត់សូត្រដ៏មានតម្លៃឡើងទៅតាមច្រកចង្អៀតតូច ហើយងងឹតស្រពិចស្រពិលដែលនាងនៅចំណាំផ្លូវច្បាស់ធ្វើឲ្យអ្នកប្រុស ដែលនៅឈរពីក្រោយ បិទទ្វាររថយន្តតាមមើលនាងដោយប្តូរទឹកមុខ។

«ខ្ញុំស្មានតែនាងភ្លេចកន្លែងនេះបាត់ទៅហើយពៅបញ្ញា!»

គេគិតម្នាក់ឯងស្ងាត់ៗក្នុងចិត្ត ទាំងភាពទុក្ខព្រួយលេចចេញតាមពន្លឺភ្នែកផ្ទុយស្រលះពីស្នាមញញឹមរបស់គេ។

ទេសាភិបាលវ័យក្មេងបោះជំហានយឺតៗតែធូន់តាមពីក្រោយនាងរហូតជាន់ ខាងលើ។ គេដឹងថានាងដើរលឿនព្រោះមិនចង់ប្រឈមនឹងនាយក្នុងទីងងឹតនោះរឹត តែមិនចង់និយាយរកនាយទៅទៀត។

«ស្មានថាមិននិយាយមិនស្គីនាងគេចពីខ្ញុំរួចពៅបញ្ញា?»គេគិតហើយសើចស្ងួត។ម៉្លោះហើយមកដល់ច្រកទ្វារដែលត្រូវចាក់សោ នាងត្រូវទាល់ច្រកព្រោះទៅមុខលែងរួច។ ស្រីស្អាតនៅទ្រឹងមិនព្រមបែរក្រោយឡើយ ដោយទំហំចិត្តមានះ ប៉ុន្តែនាងកាន់តែឮស្នូរដង្ហើមនាយកាន់តែជិតឡើងៗរហូតដល់បេះដូង នាងត្រូវលោតញាប់ហើយទីបំផុត ដៃគេទាំងពីរដែលមានកាន់កូនសោផ្ទះផង បានក្រសោបនាងពីក្រោយតែម្តង។

ពៅបញ្ញារើបម្រះចេញទាំងនៅក្តៅចិត្តរឿងមួយចំនួនជាពន់ពេក ដូចជាបាតជើងត្រូវប្រឡាក់ដីគគ្រាត សំពត់សូត្រដ៏វែងក្លាយជាក្រណាត់ជូតជណ្តើរ ហើយចុងក្រោយនៅមិនត្រូវចេញចោលពិធីមកតាមគេ។

នាងកាន់តែរើ គេក៏កាន់តែរឹតមិនលែងហើយធ្វើជាលោទៅចាក់សោបើកទ្វារតែចាក់ខុសរន្ធរហូត។

«បើមិននៅស្ងៀម មានតែឈរនៅហ្នឹងដល់ភ្លឺទាំងអស់គ្នា!»

គ្មានវិធីនាងមានតែនៅស្ងៀមហើយដកដង្ហើមយូរលែងបម្រះទុកឲ្យគេ ចាក់សោបើកទ្វារ។ ទ្វាររបើកទៅក្នុងខ្វាកគេនៅតែមិនលែងដៃហើយរឹតនាងជាប់ក្បែរ ទ្រូងធ្វើឲ្យស្រីស្អាតអស់ពីក្តៅចិត្ត ងាកមកសម្លក់គេតែ្ល។ ភ្នែកនឹងភ្នែកនៅជិតគ្នាដល់ម្លឹងហើយបបូរមាត់នាងផ្អើនហួសទៀត យុត្តនាមិនអាចទប់ស្កាត់ភាពក្រើតក្នាញ់បានសូម្បីតែមួយវិនាទីទៀត ឡើយ អ្នកប្រុសទីមួយរបស់អគ្គទេសាភិបាលហួត ស៊ីវ ភ្លេចថាទីនេះជាច្រកទ្វារ ក៏លោទៅរកបបូរមាត់នាងប្រាថ្នាបញ្ជប់កំហឹងលើផ្ទៃមុខស្រីតូច ដឹងអីនាងបានត្រៀមស្រេចហើយថាគេនឹងធ្វើយ៉ាងនេះដូច្នេះស្រីតូចបែរមកវិញលើកដៃទាំងទ្វេរុញបុរសមានមាឌមាំអស់ មួយទំហឹងកូនស្រី រហូតដល់យុត្តនាទ្រេតទ្រោតរកកលផ្ទារក្រោយទៅរកជណ្តើរដែល ងងឹតស្លុប។ ក្នុងវិនាទីតក់ក្រហល់នាងបែរជាមិនដាច់ចិត្តឲ្យគេដួលផ្ងារក្រោយ ទៅទេ ដូច្នេះស្រីអ្នកច្បាប់មិនគិតច្រើនក៏លោដៃទៅចាប់ចុងដៃអ្នក ប្រុសទាញមកវិញ ប៉ុន្តែគេជ្រុលជាទ្រេតថយក្រោយទៅហើយ ទោះទប់ជំហារប៉ុន្តែក៏នៅត្រូវតែដួលទៅដដែលគ្រាន់តែថាអាចទប់ ខ្លួនរេទៅទើរនឹង

ជញ្ជាំងពីក្រោយនោះប្រមាណបីបួនជំហានដោយមានទាំង ស្រីស្ងួនដែលចាប់ចុងដៃគេនោះ ដួលទៅបន្ថែមជាមួយគ្នាទៀត។

.....នៅក្នុងទីងងឹត.....វង់ភក្ត្រស្រីស្អាតគឺស្ថិតនៅលើទ្រូងនាយ ធ្វើឲ្យនរៈបានចិត្តស្រវាឱប នាងជាប់លែងខ្វីក្រោក។ ក្នុងភាពងងឹតមើលគ្នាមិនឃើញ នារីខំរើខ្លួនក្រោកតែក្រោកមិនបាន នាងក៏ស្រែកហៅយុត្តនាទាំង ភ័យបារម្ភព្រោះគិតថាកាយវិការគេដែលឱបនាងរឹងដូចដង្កាប់ ប្រាកដជាគេប៉ះទង្គិចខ្លាំងសន្លប់លែងដឹងខ្លួនហើយ។
«យុត្តនា! លោកយុត្តនា??»
គ្មានចម្លើយតប នាងខំលូកប្រលេះដៃគេរបូតចេញ ពីកាយហើយចុចទូរសព្ទបំភ្លឺតាមតក់ក្រហល់។ បានពន្លឺកាលណា នាងងើបមុខមកវិញពិនិត្យស្ថានភាពបុរសក្បែរកាយ ដឹងអីនាងឃើញគេគ្មានកើតអីទាល់តែសោះ បែរជាសំងំសើចស្ងាញហើយសម្លឹងភាពរលះរលាំងរបស់នាង។
អស់ពីភ័យនាងចងចិញ្ចើមហួសចិត្ត....

គេសួរឱ្យភ្លាមៈ

«មិញហៅធ្វើអី?»
គេនិយាយតិចៗបញ្ឈឺនាងព្រោះដឹងថានាងមិនទាន់ដាច់ចិត្តអស់ការ បារម្ភពីខ្លួនពិតៗ។ តែស្រីស្ងួនមិនបានសប្បាយចិត្តជាមួយទេ នាងក្រោកឡើងភ្លាមហើយដើរឡើងចោលនាយជាមួយសម្តីតបគ្រោតគ្រាតជាលើកដំបូងៈ
«កោតតែនៅរស់!»

អ្នកប្រុសក្រឡាស់ខ្លួនក្រោករឹងភ្លេចចោលការឈឺចាប់ទាំង អំបាលម៉ាន ហើយឡើងទៅលើផ្ទះតាមពីក្រោយនាងជាមួយសម្តីមិនព្រមចាញ់ៈ
«មិនទាន់បានខ្លួនមេធាវី! ស្លាប់ម៉េចកើត?»
ស្រីតូចបែរក្រោយដោយស្វ័យប្រវត្តិព្រោះមិននឹកស្មានថាសូម្បីពាក្យ សម្តីអន់ៗបែបនេះក៏គេនិយាយចេញមករួច។ នាងមិនសម្លក់ទេគឺសើចឃឹសព្រោះហួសចិត្ត....វាជាស្នាមញញឹមពេបជ្រាយ ដែលឈឺចាប់ពេកទើបនាងចេះប្រើវា.....នាងសម្លឹងចំមុខនាយ ហើយក្រសែភ្នែកនាងគឺមើលងាយអាកប្បកិរិយារបស់គេ។ នាងមិននិយាយអ្វីទៀតទេ តែទឹកមុខនាងបង្ហាញជា

ស្រែចនូវឃ្លាថា៖
«លោកជាមនុស្សជាន់ទាប ដល់ថ្នាក់ខ្ញុំស្មានអត់ដល់ទេយុត្តនា!»
គេយល់ពីអ្វីដែលនាងមានន័យតាមរយៈពន្លឺភ្នែកពេបជ្រាយនោះ ប៉ុន្តែគេញាក់ចិញ្ចើមផ្តើន
វិញ៖
«ខ្ញុំក៏អត់ទាមទារឲ្យនាងពេញចិត្តដែរពៅបញ្ញា!»
គេប្រើឃ្លាសម្ងាត់នេះតាមរយៈកាយវិការដាក់នាង។ នាងសម្លក់នាយហើយងាកមុខចេញតែ
ត្រូវគាំងពន្លឺភ្នែកនិងអ្វីមួយ ក្រោយខ្នងនាយ។
នោះគឺដើមផ្កាសារិកាកែវដែលស្វិតក្រៀមក្រញង់សល់ស្លឹកតិចតួចគ្មាន សូម្បីផ្កាមួយទងនឹង
គ្រាន់បង្ហើរក្លិនកំដរបរិយាកាសសឹកសង្គ្រាម រវាងនាងនិងគេ។
នាងនឹកឃើញដល់អ្វីមួយ.....ហើយទ្រឹងក្រសែភ្នែកនៅទីនោះ។
....នៅក្រោមពន្លឺភ្លឺស្រទន់នៃរាត្រី១៥កើត ដើមផ្កាសារិកាបោះបង់សម្រស់ហើយក្រៀម
ស្រពោនទៅតាមអាយុកាលដ៏វែង របស់វា តែក៏បង្ហាញឲ្យស្រស់ស្រីដឹងថា បុរសនេះមិនបាន
យកចិត្តទុកដាក់ថែទាំវាឡើយ។

យុត្តនារវើភ្នែកទៅកាន់ទីនោះ គេក៏យល់ពីអ្វីដែលស្រីស្អាតកំពុងគិត។
អគ្គនាយកធនាគាររវើភ្នែកចេញ លាក់លួចភាពស្រងូតរបស់ខ្លួនហើយដើរហួសចូលទៅក្នុងផ្ទះ
តូចដែល ស្ងាត់ជ្រងំក្រោមកម្លាំងវាយោផាត់កំដរតិចៗទុកចោលកញ្ញាអភិជននៅ
ស្រងេះស្រងោចម្នាក់ឯង។
«យុត្តនា! ទីបំផុតដើមផ្កានេះស្លាប់ហើយ! គឺវាដូចជាដង្ហើមចុងក្រោយនៃអនុស្សាវរីយរបស់
យើងដែរ!»
នាងនិយាយប្រាប់ខ្លួនឯងក្នុងបេះដូងទាំងក្តុកក្តួល។
នាងនៅស្ងាត់ស្ងៀមអស់ចិត្ត ទម្រាំកាត់ចិត្តថាលែងផ្តោតសម្លឹងរុក្ខជាតិនោះព្រោះពន្លឺភ្លើង
ត្រូវបានចុចបំភ្លឺមកពីក្នុងផ្ទះតូច។
ហើយរវើភ្នែកទៅរំលងកូនផ្ទះតូចសម្លឹងទៅរានហាលខាងមុខ ដែលនរៈម្ចាស់លំនៅឋានកំពុង
ឈរកាន់ដបប៊ីយែរក្នុងដៃហើយបែរខ្នង ដាក់នាង។
អ្វីមួយជំរុញឲ្យនាងដើរឃើតៗចូលទៅ....
កណ្តាលផ្ទះតូចត្រជាក់ល្ហឹមក្រោមផ្សេងសន្សើមរាត្រី ស្រីតូចរវើភ្នែកសម្លឹងជុំវិញទីនោះ ហើយ

បញ្ឈប់ក្រសែភ្នែកនៅលើទីតម្កល់ជើងធូបបុរសស្ត្រីមួយគូដែល ញញឹមពព្រាយក្នុងរូបថត។ នាងសន្សឹមៗដាក់ទូរសព្ទលើតុក្បែរនោះ ហើយលើកដៃសំពះអ្នកដែលនាងស្គាល់ច្បាស់ថាជាមនុស្សជិតស្និទ្ធរបស់ ឪពុកខ្លួន។

«អ៊ំប្រុសអ៊ំស្រីឆាប់ទៅចោលគេពេក បានជាគេបញ្ឈប់ជីវិតខ្លួនដោយវិធីនេះ?»

នាងគិតស្ងាត់ៗហើយចាប់ស្រងេះស្រងោចចិត្ត។

សំឡេងបុរសម្ចាស់ផ្ទះលាន់មកតិចៗតាមកម្លាំងខ្យល់៖

«គិតថាមេធាវីមិនអន់ចិត្តទេ ដែលឲ្យនាងចុះស្នាមរាត្រីទីមួយនៅផ្ទះដ៏ក្ររហាមនេះ!»

ស្រីតូចស្ទាងអារម្មណ៍ភ្លាមពីភាពប៉ាចរហាចហើយប្រឈមមុខជាមួយវិនាទីថ្មីមួយដែលរំជួយចង្វាក់ដង្ហើម។

នាងបុកពោះតិចៗ តាមសភាវៈជានារីវ័យក្រមុំ និងមិនដែលសូម្បីតែគិតពីរឿងរួមរស់ជាមួយបុរសមុនរៀបការ។

«គេពិតជាធ្វើយ៉ាងនេះមែន?»

នាងសួរខ្លួនឯងទាំងចុងដៃត្រជាក់បន្តិចម្តងៗ។

ភក្តិស្រីប្រែជាសស្លេក ហើយកន្ទុយភ្នែកនាងទទួលដឹងថាគេនោះកំពុងបែរខ្លួនមកសន្សឹមៗជាមួយដបប៊ីយែរក្នុងដៃ។

សាច់នាងចាប់ផ្តើមប៉ះខ្យល់ត្រជាក់ ហើយនាងទើបតែដឹងថា រាងកាយនាងគឺបិទបាំងតែត្រឹមដើមទ្រូងចុះប៉ុណ្ណោះ ចំណែកអាវចងពុងនេះ គឺកំពុងតែបន្ថែមភាពគ្រោះថ្នាក់ដល់នាង។ នាងងើបមុខសម្លឹងសត្រូវ ក្នុងវិនាទីដែលមានពិភាល់បំផុតថានាងជាភាគីចាញ់សង្គ្រាម ក៏ដើម្បីឲ្យប្រាកដថា តើនាងពិតជាកំពុងប្រឈមនឹងគ្រោះថ្នាក់មែនឬយ៉ាងណា។

យុត្តនាញញឹមដោយក្រសែភ្នែកត្រជាក់.....គេមិននិយាយតែគេបន្ថែមហេតុផលឲ្យខ្លួនឯងក្នុងចិត្តស្ងាត់ៗ...

«ឧកញ៉ាប៉ានាង បងប្រុសក្មេងក្អាងរបស់នាង អើតក្បាលមកជួយនាងបានដែរអត់ពៅបញ្ញា?»

នៅក្រោមពន្លឺថ្លាស្រទន់នៃរាត្រីកាលពន្លឺភ្នែកស្រីស្រស់ទៅជា ថ្លាឆ្វង់ ហើយនាងសម្លឹងមកនាយមិនដាក់ភ្នែកជាសញ្ញាថានាងភ័យ ហើយមិនហ៊ានប្រហែសសូម្បីតែមួយដង្ហើម។

គេចាប់ឈានមក នាងក៏ឈានថយ។

គេញញឹម នាងព្រិចភ្នែកព្រោះភិតភ័យ....ទីបំផុតនាងក៏ទាល់ដល់ជញ្ជាំងបណ្តោយ នរៈ

ឈានមកក្បែរសូម្បីតែដង្ហើមក៏ដកបន្ទរគ្នាទៅវិញទៅមក.....
«យុត្តនា...!»
នាងមិនអាចនិយាយអ្វីលើសពីហៅឈ្មោះគេឡើយ ព្រោះគាំងអណ្តាត។ នាងមិនចង់អង្វរប្រុស ម្នាក់នេះ រឹតតែមិនអាចគេចវេះ ព្រោះនាងដឹងតាំងពីដំបូងថាគេត្រូវការបែបនេះបានជាគេចំណាយ កម្លាំងចាប់ជនបរទេសនោះឲ្យប៉ានាងបានរួចខ្លួន ។

តាំងពីចេញពី apartment ជាន់ទី៦ នាងដឹងស្រេចថា ថ្ងៃណាមួយជាថ្ងៃដែលនាងត្រូវទូទាត់សងគេ នឹងមកដល់ តែមិនស្មានថាវារហ័សយ៉ាងនេះហើយគ្រោតគ្រាតយ៉ាងនេះឡើយ។ គេបង្ខំនាងចាកចោលពិធី ក្នុងចំណោមអ្នកមានមុខមាត់នានា ឲ្យនាងឡើងមកកាន់ទីនេះទាំងរបូតស្បែកជើង ក្នុងស្ថានភាពដូចជាមនុស្សគ្មានសិទ្ធិសូម្បីតែមានភាពថ្លៃថ្នូរ សមរម្យសម្លាប់ខ្លួនឯង ពេលនេះគេប្រាថ្នាយកវត្ថុល្អបំផុតក្នុងជីវិតនាងទាំងដឹងហើយថា វាមិនខុសអីពីសម្លាប់នាងដែរ។
.....លោកអាក្រក់...សាហាវលើសពីអ្វីដែលខ្ញុំគិត....លោកផ្លាស់ប្តូរអស់ហើយ យុត្តនា....បើលោកគិតថាខ្ញុំនឹងស្រក់ទឹកភ្នែកមួយតំណក់អង្វរករលោក ....លោកដេកយល់សប្តិទៅ....! បានតើ.!!...បើលោកចង់បានអញ្ចឹង....ឲ្យវាចប់សព្វគ្រប់ដូចដែលលោក សម្លាប់ដើមសារិកាកែវដែលយើងខំដាំស្រោចទឹកមកជាមួយគ្នានោះដែរទៅ...
....គិតហើយនាងខាំមាត់ទប់ទឹកភ្នែកដែលរកកលតែរមៀល....ក្នុងពេលម្រាមដៃ បុរសអ្នកលេងរមៀលប្រឡៃលើស្មាទន់រលោងរបស់នាង ហើយវាចាគេលាន់មកតិចៗល្មមតែឮ ហើយឈឺផ្សាដល់បេះដូង៖
«តាមពិត ....យើងមានទៅអន់អីប៉ុន្មានពៅបញ្ញា»
ស្នាមញញឹមរបស់អ្នកប្រុសទីមួយ កាន់តែបង្កាត់ភ្លើងកំហឹងរោលរាលក្នុងបេះដូងស្រីតូច។ នាងលេចភាពជូរចត់ពេញបេះដូង ព្រោះឆ្អែតចិត្ត។ ពៅបញ្ញាងាកមុខទៅទីផ្សេងតែក៏លែងគេចលែងរើ។សំឡេងមេធាវីតូចលាន់ មកស្មើធេងតែមិនអាចលុបចោលភាពទោមនស្សបាន៖
«ធ្វើអីធ្វើទៅ! នឹងអាលខ្ញុំត្រលប់ទៅវិញ!»
សម្តីនាងគួរណាស់តែឲ្យយុត្តនាបានដៃក្នុងការលោតរំលងសម្បជញ្ញៈ ក្នុងនាមជាកូនប្រុសអ្នកជាមនុស្សម្នាក់ដែលឪពុកម្តាយមានការអប់រំហើយបានបន្តពុទ្ធិ នោះមកឲ្យនាយពេញ

បរិបូរណ៍ តែមិនដឹងយ៉ាងម៉េចវាបែរជាធ្វើឲ្យកំហឹងនាយកាន់តែផ្ទុះ។
«នាងរឹងរូសពេកហើយពៅបញ្ញា....ស្រីសាហាវ!»
គេគិតភ្លាមក៏បន្លឺចេញមកភ្លាមតាមចិត្តមានៈ៖
«ចង់ដែរតើហ្អី?»

តើខឹងអ្វីឲ្យលើសពីនេះទៀតបានជ្រុលជាខឹងដល់១០០អង្សាទៅហើយ? កូនស្រីពៅរបស់ឧកញ៉ាប៉ែន ពេជ្រ សុខចិត្តសម្លឹងឥដ្ឋមិនសម្លឹងមុខប្រុសម្នាក់នេះឡើយ តែនាងមិនព្រមបញ្ឈប់ការតបតតាមរយៈសម្ដីទេ នាងយល់ថាយ៉ាងណាក៏ដោយលទ្ធផលចុងក្រោយនោះជៀសមិនបានទៅហើយ នាងមានរឿងអីត្រូវទុកមុខឲ្យនាយទៀត?
«ទោះខ្មើមប៉ុណ្ណា ជ្រុលជាជំពាក់ទៅហើយ! សងឲ្យវាចប់កម្មពៀរនឹងគ្នាតែម្ដងទៅ!»
យុត្តនាខាំមាត់.....គេលែងដៃពីស្មានាងហើយទាញភ្ញើយវង់ភក្ត្រទ្រវែង ពេញណែនដោយភាពរឹងត្អឹងនោះមកប្រឈមនឹងខ្លួន ជិតសែនជិតដល់ថ្នាក់នាងគេចលែងមើលភ្នែកនាយក៏មិនបាន។
ទេសាភិបាលវ័យក្មេងខាំមាត់លាយស្នាមញញឹមជូរចត់៖
«អញ្ចឹង? បើមែន ចាំបាច់អីប្រើល្បិចអន់ៗច្រើនម៉េះអ្ហះ? ចាំបាច់អីចង់សម្លាប់ម្ចាស់បំណុលបំបាត់ដាន? បន្ទាប់មកមិនបានសម្រេចលេងល្បិចទីពីរចង់អូសម្ចាស់បំណុលទម្លាក់ គុក? នេះអ្ហេះរបៀបសងបំណុលរបស់ពួកអ្នកថ្លៃថ្នូរ ពួកអ្នកចេះច្បាប់ច្រើន???»
ស្រស់ស្រីបញ្ចេញភាពងឿងឆ្ងល់តាមពន្លឺភ្នែក នាងគិតមិនយល់ ឆ្លើយក៏មិនទាន់ ព្រោះយល់ថាវាអយុត្តិធម៌ពេក សម្រាប់ព័ត៌មានចុងក្រោយនេះ ហើយភ្លាមៗនោះបបូរមាត់នាងស្រាប់តែលែងអាចបញ្ចោបាន ព្រោះបុរសដ៏គ្រោតគ្រាតបានគ្រប់គ្រងនៅទីនោះជាប់ ព្រោះមិនចង់ឲ្យនាងជ្រុលសម្ដីធ្ងន់ធ្ងរលើខ្លួនលើសពីនេះទៀត។

កាលពីលើកទីមួយនៅ Apartment ជាន់ទី៦យុត្តនាមិនអាចថើបបបូរមាត់នាងឲ្យបានដល់៣វិនាទីឡើយ ដោយសារនាងជាន់ជើងគេ តែលើកនេះយុត្តនាមានអារម្មណ៍ថាភាគីខាងស្រីមិនរើសោះទោះបីដំបូង ៗនាងលើកដៃទាំងពីរមករងពីមុខទ្រូង តែចុងក្រោយនាងក៏នៅតែមិនច្រានគេចេញ។
«ស្រីចិត្តទឹកកក!!! នាងប្រាកដជាចង់សងឲ្យរួចគ្នាឆាប់ៗមែន?»
គេគិតបណ្ដើរបន្តក្រេបជញ្ជក់រសជាតិលើបបូរមាត់តូចក្រពុំនោះ ប្រាថ្នាបង្កាត់ភាពរោលរាល

ឲ្យខ្លួនឯង ព្រោះដឹងថាសកម្មភាពសោះអង្គើយរបស់នាងកំពុងធ្វើឲ្យខ្លួនកើនឡើង នូវភាព អៀនខ្មាស ហើយនិងអស់អារម្មណ៍ត្រេកត្រអាល។
ទោះខំប្រឹងបន្លប់ចិត្តដើម្បីប្រដៅនាងកុំឲ្យនាងរឹងរូសពេក តែក៏សម្ដីនាងនៅតែវាយប្រហារ ដដែលៗមកលើអារម្មណ៍គេឲ្យឈឺផ្សា ជាមួយភាសា«ខ្លើម»ដ៏អសុរោះដែលប្រុសៗស្អប់នឹងព្ទ បំផុត តែនាងបែរជានិយាយចេញមកព្រោះតែខឹងគេដល់បន្ទុក។
ទីបំផុតគេក៏លែងនាងចេញពីរង្វង់ដៃ ហើយមើលមុខនាងដែលមិនយំសោក ហើយមិនរណប គ្រាន់តែក្រហមដូចងើកភ្លើង។

យុត្តនាមើលឃើញច្បាស់ហើយថា ស្នេហាដែលខំបញ្ចេញតាមបបូរមាត់នាយមិនអាចមាន លទ្ធភាពរំលត់ភ្លើង កំហឹងក្នុងចិត្តនាងសូម្បីមួយចន្លោះណានោះទេ វាជាសក្ខីភាពថានាង គ្មានមនោសញ្ចេតនាទន់ភ្លន់អ្វីមួយចម្រៀកឲ្យ ខ្លួនឡើយ។

បើដូច្នេះ ទោះបីបានខ្លួនប្រាណនាងតូចក៏មិនខុសអ្វីពីរួមរស់ស្នេហាជាមួយ តុក្កតាជ័រដូចគ្នា។ គេលែងនាងតែភ្នែកនៅតែសម្លឹងនាងដោយភាពមិនសុខចិត្ត។ អ្វីដែលអ្នកឃើញ គឺស្រីតូច កំពុងឈ្ងោកជូតមាត់ដោយមិនរវល់សម្លឹងតបមកនាយឡើយ។
គេគិតម្នាក់ឯងជាមួយកែវភ្នែកសោកសៅ៖

«នាងស្អប់ខ្ញុំដល់ថ្នាក់នេះ ខ្ញុំទើបតែដឹង ពៅបញ្ញា!»

ពេលគេសម្លឹងមក នារីឈ្ងោកមុខសម្លឹងកម្រាលឥដ្ឋ។

នាងយល់ថាក៏នៅគ្រាន់បើដែរដែលមិនអាចបន្តបំពានចិត្តនាងតទៅ ទៀត តែសកម្មភាពគេ មុនៗនេះវាជ្រុលឲ្យនាងឈឺហួសហេតុទៅហើយ នាងគ្មានផ្លូវដែលដូរការគិតមករកមើល អំពើល្អគេជាថ្មីឡើយ។

សូម្បីតែមុខគេក៏នាងមិនចង់ប្រឈម។ នាងនិយាយដោយខាំមាត់៖
«សប្បាយចិត្តឬនៅ?....ខ្ញុំទៅបានហើយមែនទេ?»
មិនដឹងយ៉ាងម៉េច ភាពឆ្មើងឆ្មៃរបស់នាង ធ្វើឲ្យនាយចេះតែឆេះឆួលភាពមានះឡើង។ ពេល នាងរេខ្លួនសំដៅទ្វារ គេលើកដៃទៅបង្ខាំងភ្លែត។
«នាងអន់ដល់ថ្នាក់ខ្ញុំអត់អារម្មណ៍រលីងពៅបញ្ញា! តែបំណុលត្រូវតែសង ! ខ្ញុំប្រហែលរកប្រុស ផ្សេងឲ្យមកទារនាងជំនួសខ្ញុំ ក្រែងមានគេលេបនាងចូល!»

ស្រីស្អាតងើបមុខភ្លែតមកប៉ះនឹងបបូរមាត់អ្នកប្រុសដែលក្របួចខ្ចី នាង។ គេញាក់ចិញ្ចើម បញ្ជាក់ផ្ដើននាងថាអ្វីដែលនាងឮនោះជាការពិត។ នៅតែមិនអស់ចិត្ត គេនិយាយបន្ថែមផ្ទួងៈ «បើខ្ចីមអាមួយនេះខ្លាំង ចាំមើលអាមួយផ្សេងទៅមើល៍ ក្រែងវាអេមជាង! ដល់ពេលហ្នឹងមិនបាច់និយាយអរគុណក៏បាន!»

នាងនៅទ្រឹងសម្លឹងមុខនាយដោយភ្នែកគ្រលួង ព្រោះហួសចិត្តនឹងចរិតដ៏ឈ្លើយបំផុតពិបាករកក្នុងលោក។ គេបន្តមកទៀតរឹងៈ
«ប្រុសៗក្នុងក្រុមខ្ញុំមានច្រើនគួរសម បើថាខ្ញុំសុភាពពេកមិនត្រូវចិត្តនាង ហើយបើថា មួយនាងមិនគ្រប់ ចាំខ្ញុំរកឲ្យបានពីរបីនាក់តែម្ដងមេធាវី»
ដោយស្វ័យប្រវត្តិពៅបញ្ញាយារដៃស្ដាំទៅរកប្រអប់មាត់អ្នកប្រុស ម្ចាស់ផ្ទះ ព្រោះលែងចង់ទុកពេលឲ្យគេបន្ថែមឃ្លាទីបួនមក។ ទឹកភ្នែកនាងត្រូវបានទប់យ៉ាងល្អដូច្នេះវាបញ្ជូនការឈឺចាប់និង កំហឹងទាំងអស់មកលើបាតដៃស្រី ធ្វើឲ្យមួយកំផ្លៀងនោះដាស់យុត្តនាឲ្យស្វាងចេញពីភាពទោសៈឆ្កួត ឡប់របស់គេ។
គេងើបមុខមកវិញទាំងថ្ពាល់មួយចំហៀងនៅស្ពឹក។
មិននឹកស្មានថា ស្រីស្រស់នៅតែមិនអស់ចិត្ត នាងយារមកជាលើកទីពីរ តែលទ្ធផលគឺបាតដៃទន់ ល្វក់របស់នាងត្រូវទៅនៅក្នុងប្រអប់ដៃនាយ។
«កុំសម្បើមពេក ពៅបញ្ញា! ការអត់ធ្មត់របស់មនុស្ស វាមានព្រំដែនណ៎ា!»
នាងស៊ើចខឹកទាំងឈឺចិត្ត នាងនិយាយវិញរ៉ាវៈ
«អូអត់ធ្មត់!? អស្ចារ្យមែនដែលទើបមកឮថាពួកអ្នកលេងកាប់ចាក់ចេះអត់ធ្មត់!.....មិន បាច់ទេ!!! ឮអត់ ខ្ញុំអត់ត្រូវការ....ចង់ទះខ្ញុំវិញពេលណាក៏បាន.....មិនហ៊ានជំពាក់គុណ លោកទេ.....»
យុត្តនាព្រិចភ្នែកព្រោះកំហឹងឈានដល់កម្រិតពិបាកទប់អារម្មណ៍។ នារីនេះមិនត្រឹមតែមិនដឹងគុណ ថែមទាំងក្បត់ចិត្តអ្នកជួយរៀបផែនការតាមព្យាបាទនាយពីក្រោយខ្នង ម្ដងជាពីរដងលើកនេះនៅតែមិនចោលចរិតរឹងរូស សូម្បីឫកពាសមជាមនុស្សស្រីតែបន្តិចក៏គ្មាន ទីបំផុតលេចចរិតដើមចេះប្រើពាក្យបញ្ឈឺមួយបេន ។

គេមិនទាន់ដឹងថាត្រូវប្រដៅនាងយ៉ាងណាផង ស្រាប់តែទូរសព្ទនាងលើកូនតុរោទ៍មកច្រេកធ្វើឲ្យអ្នកប្រុសដៀង ភ្នែកទៅវត្ថុនោះ។

អក្សរ «PaPa» អណ្តែតលើអេក្រង់.....
ពៅបញ្ញាក្តុកក្តាក់ក្នុងចិត្ត...នាងដឹងថា ឪពុកកំពុងតាមរក ហើយបើឲ្យលោកដឹងថានាងកំពុងនៅទីនេះ ជាមួយមនុស្សបែបនេះក្នុងស្ថានភាពរបៀបនេះ តើលទ្ធផលចុងក្រោយគឺអ្វី?។ ភក្ត្រស្រីប្រែជាស្លេក.....ធ្វើឲ្យប្រុសស្អាតលេចចេញស្នាមញញឹម ជំនួសឲ្យភ្លើងកំហឹង គេលែងដៃនាងឲ្យរបូតចុះក្រោមត្រង់ធ្លូ ហើយឈោងទៅរកទូរសព្ទនោះក្រោមភាពតក្កមារបស់ពៅបញ្ញា។
នាងបើកភ្នែកធំៗតាមសម្លឹងនាយទាំងដឹងហើយថា គេបម្រុងធ្វើយ៉ាងណា។
វាជារឿងដ៏ហានិភ័យប្រសិនបើគេឲ្យប៉ានាងដឹងថាថ្មើរណោះគេកំពុង នៅជាមួយនាង ហើយបើគេទប់ចិត្តមិនបានដល់ថ្នាក់និយាយរឿងទាំងអស់នោះ ទៅប្រាប់លោកទៀត ការប្រឹងប្រែងរបស់នាងនឹងចប់។
ក្នុងពេលដែលបេះដូងនាងលោតរកកលនឹងគាំង ម្រាមដៃគេបានទៅលោលើប៊ូតុងសម្រាប់ទទួលស្រេចទៅហើយ។ ភ្នែកគេសម្លឹងមកនាងជាមួយស្នាមញញឹមដែលធ្វើឲ្យស្រីតូចព្រឺ សម្បុរ។ គេនិយាយខ្លីៈ
«បើកូនយ៉ាប់ពេក និយាយជាមួយឪក្រែងសប្បាយចិត្តជាង!»
ពៅបញ្ញាថ្លោះទឹកមុខ នាងស្ទុះមកក្បែរគេជាមួយភាពអង្វរករនឹងចុះចាញ់លេចចេញតាមគ្រាប់ ភ្នែកទាំងគូ។ ស្រីម្នាក់នេះគិតឪពុកជាងជីវិតខ្លួន យុត្តនាមិនមែនមើលប៉ុណ្ណឹងក៏មិនយល់នោះទេ នាងទាល់ច្រកដល់ថ្នាក់ចង់ពោលពាក្យលន់តួគេភ្លាមៗទៅហើយ គ្រាន់តែថាមាត់នាងហាពាក្យអង្វរនាយមិនរួចព្រោះមុននេះនាងក៏ ខ្លាំងសម្បើមណាស់ដែរ។

ស្ថានភាពនាង ធ្វើឲ្យយុត្តនាកាន់តែបានចិត្ត។

នៅពេលភាគីស្រីស្ទុះមកក្បែរហើយសម្លឹងចំភ្នែកនាយដោយទុក្ខ ព្រួយ គេក៏ចាប់ទន់ចិត្តតិចៗដែរ តែសម្តីនាងមួយម៉ាត់ៗមុននេះវាចុកពេក ដល់ថ្នាក់អ្នកលេបកំហឹងវិញមិនកើតភ្លាមៗទេ។
ដៃគេចុចប៊ូតុងទទួលរឹង ទាំងស្នាមញញឹមរំលេចថ្លាល់ខួចជាកិច្ចឪដងទៅស្រីស្អាត។

ក្នុងពេលដ៏ទាល់ច្រកនាងខំគ្រវីក្បាលមិនហ៊ានបញ្ចេញសំឡេង ក្នុងន័យអង្វរនាយឲ្យកុំហាមាត់សូម្បីតែមួយម៉ាត់ តែនាងគ្មានសង្ឃឹមថាយុត្តនាព្រមនោះទេ ព្រោះគេលើកទូរសព្ទមកដាក់ក្បែរមាត់ទៅហើយ ។ គ្មានអ្នកណាស្មានដល់ទេថា ហេតុតែការពារមិនឲ្យឪពុកដឹងពី

ស្ថានភាពដ៏អាម៉ាស់របស់ខ្លួន ស្រីអ្នកច្បាប់ដាច់ចិត្តឈោងទៅឱបក្រសោបស្មាធំមាំទាំងសង របស់ ទេសាភិបាល ដែលទើបតែធ្វើឲ្យនាងឈឺចាប់។
ហើយដើម្បីធានាសុវត្ថិភាពថាសំឡេងគេមិនអាចលាន់ឆ្លងដល់ទូរសព្ទ គឺនាងមានតែជំទើតជើងហើយប្រើបបូរមាត់ទៅបង្រ្គបលើប្រអប់សូរសម្លេង របស់នាយ។
.....ងងើកភ្លើងចិត្តកំពុងឆេះឆួលដល់១០០អង្សា រកតែទម្លាក់ដីក្រេមិនទាន់កើត ស្រាប់តែត្រូវបបូរមាត់ក្រអូបប្រហើរនៃនារីអ្នកច្បាប់ចាប់ពន្លត់ ដោយវិធីដ៏កម្រប៉ែបនេះធ្វើឲ្យកំហឹងនរៈទាំងអំបាលម៉ានរបូតធ្លាក់ ខ្សាកមកដល់ចុងជើង។
....នេះជាអាថ៌កំបាំងដ៏មានអាយុកាលវែងបំផុតក្នុងភពផែនដី។
ពៅបញ្ញាគួរតែដឹងហើយថាបុរសមិនព្រមចាញ់ភាពមានះរឹងត្អឹងរបស់ នាងទេ ប៉ុន្តែគេចាញ់ភាពទន់ភ្លន់និងផ្អែមល្ហែមរបស់នាង។

អ្នកប្រុសទីមួយរបស់ ហួត ស៊ីវ ទន់ដៃស្ទើររបូតធ្លាក់ទាំងទូរសព្ទ ហើយរាងកាយអ្នកខំទប់ការតោងថើបរបស់នារីទាំងបេះដូងហោះហើរ។
ដោយសារនាយខ្ពស់ពេកហើយស្រីតូចគ្មានស្បែកជើងទៀត បបូរមាត់នាងកាន់តែប្រផឹតប្រផើយពីមាត់នាយធ្វើឲ្យនរៈនឹកស្ដាយ ស្រណោះមិនចង់ឲ្យលាគ្នាទៅទាំងយ៉ាងនេះឡើយ គេក៏ឈោងដាក់ទូរសព្ទដែលឮតែសំឡេងលោក ប៉ែន ពេជ្រ ហៅល្ងើយៗនោះចោលទៅលើតុវិញដោយប្រើដៃទាំងទ្វេមកក្រសោបស្រី តូចពេញទំហឹង ហើយជួយចាប់ចង្កេះនាងឲ្យនៅស្មើបបូរមាត់គ្នាផង។
ដឹងខ្លួនមកវិញ....ពៅបញ្ញារវើ្នកទាំងភ័យបារម្ភ នាងចង់ដកខ្លួនថយក៏ដឹងថាជ្រុលពេលហើយព្រោះបុរសចាប់ផ្ដើមបន្ត ល្បែងស្នេហ៍លើបបូរមាត់ដែលមុននេះមហាគ្រោតគ្រាតដាក់គ្នា ។
ទម្រាំគេថើបនាងអស់ចិត្ត ហើយដកបបូរមាត់ចេញពីនាងជំនួសមកវិញដោយខ្សែភ្នែកស្រទន់ នាងក៏ប្រើកន្ទុយភ្នែកសម្លឹងគេដោយអៀនខ្មាស ហើយលូកដៃទៅក្រោយចង្កេះខ្លួនប្រលេះដៃគេចេញស្រាលៗ។

ម្រាមដៃនាងដែលប៉ះប្រអប់ដៃនាយទន់សែនទន់ ធ្វើឲ្យយុត្តនាដែលមានះចង់ឱបចង្កេះនាងយូរជាងនេះក៏មិនដាច់ចិត្ត ទទឹងនឹងការប្រលេះចេញរបស់នាងបាន។
ស្រីស្អាតងាករឹងទៅរកសំឡេងឪពុកក្នុងពេលដែលភាគីចាញ់ស្នេហ៍ នៅតែតាមសម្លឹងនាង

មិនព្រមដកខ្សែភ្នែករំភើបនោះចេញនៅឡើយទេ។
គេមិនហើបមាត់ព្រោះអាណិតនាងដែលរលះរលាំងទៅលើកទូរសព្ទមកនិយាយ ។
អ្នកប្រុសបែរទៅរកដបប៊ីយែរហើយបន្តក្រេប ក្នុងពេលត្រចៀកនៅតែប្រឹងផ្ទៀងស្ដាប់កិច្ចសន្ទនារបស់ស្រីតូច។
«លោកប៉ា! កូន....កូន....ជាប់ផ្លូវ....កូនកំពុងត្រលប់ទៅផ្ទះ! កូនជិតទៅដល់ហើយ! លោកប៉ាសម្រាន្តទៅកុំបារម្ភអី!»
គេនៅអត់ធ្មត់រង់ចាំឲ្យនាងលួងលោមឪពុកតែបេះដូងគេមិនបានស្ងប់ទេ ព្រោះកិរិយាសុភាពរមទមរបស់នាងជាមួយអ្នកមានគុណវាផ្ទុយស្រលះទៅ នឹងភាពរឹងរូសដែលនាងខំសម្ដែងផ្គើនគេកាលពីមុននេះ។
ស្រមោលស្រីពៅកាលពីអតីតកាលវិលត្រលប់មកវិញក្នុងបេះដូងបុរស ពនេចរ។ គេងាកសម្លឹងនាងភ្លៀកៗរហូតដល់លែងឆ្ងាញ់នឹងពពុះប៊ីយែរ ហើយដាក់ដបទុកទៅវិញដោយឈានជើងដើរមួយៗតម្រង់មករកស្រីតូច។
ក្រោមពន្លឺខែស្រទោស្រទន់....យុត្តនាដឹងថាបើពេលនេះអ្នកមិនឱបនាងឲ្យជាប់ក្នុងរង្វង់ដៃតើចាំដល់អង្កាល់ទៀត?
គេឱបក្រសោបនាងពីក្រោយហើយដាក់ក្បាលផ្ដេកផ្ដួលទៅលើស្មាឆ្វេង របស់នាង ធ្វើឲ្យស្រីតូចអាក់ខានការជជែកតាមទូរសព្ទបន្តិចព្រោះ ភ្ញាក់ផ្អើល។
ពៅបញ្ញាក៏មិនហ៊ានច្រានគេចេញទេ ព្រោះមិនចង់ឲ្យមានសំឡេងអ្វីមួយលាន់ឮដល់ខាងឪពុក។
«កូនជម្រាបលា លោកប៉ា!»
នាងចុចបិទទូរសព្ទឯយុត្តនាធ្មេចភ្នែកទទួលយកក្ដីសុខ ដែលចាកផុតភាពឯកោមួយពេល។...គេមិនមាត់ ....នាងដៀងភ្នែកសម្លឹងគេ។
....ទោះយ៉ាងណាស្រីស្ងួនដកដង្ហើមធូរទ្រូងព្រោះអ្វីៗហាក់វិលមកធម្មតាវិញ...ដែលរឹតតែសំខាន់គឺប៉ានាងមិនអី។

ចង្វាក់ដង្ហើមគេលាន់មកកំដរនាងក្បែរថ្ពាល់ខាងឆ្វេង ធ្វើឲ្យនាងយល់ដោយខ្លួនឯងថា សម្ដីត្រមាំងត្រមោកនិងក្រអឺតក្រទមរបស់គេទំនងជាគ្មានការពិតទេ គេជាមនុស្សមាននិស្ស័យហាស៊ីគ្រោតគ្រាតតែក៏មិនមែនគ្រោះថ្នាក់ ពេកដែរ។

នាងស្តាយក្រោយតិចៗដែលមុននេះបានថាឲ្យគេដំណំៗ។ ប្រាជ្ញារបស់មនុស្សស្រីស្រាប់តែលេចមកវិញពីពេលណាមិនដឹង។

នាងដាច់ចិត្តនិយាយតិចៗទៅរកគេ៖

«ខ្ញុំសុំទៅផ្ទះសិន! យប់ជ្រៅហើយ!»

គេនៅតែមិនបើកភ្នែក តែសំឡេងគេលាន់មកតិចៗក្បែរត្រចៀក៖

«បង្កាត់ភ្លើងហើយ ដើរចោលអញ្ចឹង?»

និស្សិតស្រីនៃប្រទេសអភិវឌ្ឍន៍ទោះមិនធ្លាប់ចុះស្នាមក្នុងរឿង ស្នេហាប្រុសស្រីដល់ថ្នាក់ស៊ីជម្រៅ តែនាងយល់ពីស្ថានភាពរបស់គេហើយចាប់អារម្មណ៍ថាអាណិតគេ។

ភ្លាមនោះនាងនឹកឃើញឡើងវិញដល់រាត្រីមួយនៅ Apartmentជាន់ទី៦ ដែលនៅយប់នោះគេតែម្នាក់គត់ មានលទ្ធភាពជួយផ្ទះនាងឲ្យស្ងប់ស្ងាត់ពីរលកសង្ស័យ។

«យើងកើតស្អីបានជាល្ងាចនេះឆាប់ភ្លេចគុណគេ ហើយដៀលត្មះគេអាក្រក់អាក្រីម្ល៉ឹង! ទោះយ៉ាងណាគេជាមនុស្សដែលជួយយើងក្នុងពេលយើងត្រូវការបំផុត! មកពីយើងអន់ចិត្តនឹងភាពត្រមាំងត្រមោករបស់គេពេក ? បើទោះជាគេពិតជាចង់បានខ្លួនប្រាណយើង ក៏វាសមល្មមទៅហើយចំពោះអ្វីដែលយើងជំពាក់គេ! តែម្តងជាពីរដង គេហាក់ដូចជាលឹបលេ ធ្វើឲ្យយើងខឹង? បើគេពិតជាត្រូវការបំពេញតណ្ហាមែន ក៏មិនចាំបាច់រង់ចាំដល់ពេលនេះឯណា?»

នាងប្រលេះដៃគេចេញថ្នមៗ។

«លោកមិនចង់ធ្វើអញ្ចឹងទេ កុំខំសម្តែងជាមនុស្សអាក្រក់!»

នាងនិយាយតិចៗ។

តែអ្នកប្រុសរបស់អភិជន ហួត ស៊ីវ បើកភ្នែកព្រឹមហើយសើចកក្អឹក៖

«អ្នកណាថា? ចង់កម្លាខ្លួនឯង? ស្មានថានិយាយអញ្ចឹង អាចបានរួចខ្លួនមេធាវី?»

គេបង្វែរនាងមកទោះនាងឈ្ងោកមុខជ្រប់ក៏ដោយ គេនៅតែសម្លឹងនាងស្ទើរភ្លេចដកដង្ហើម។

ពៅបញ្ញានិយាយបន្ត៖

«សូមទោស! ដែលនិយាយអាក្រក់ៗដាក់លោក!»

យុត្តនាកាន់តែញញឹមបង្ហាញសម្រស់ស្រស់សង្ហាតាមបបូរមាត់៖

«ស្មានថាពាក្យអស់នេះជួយនាងបានពៅបញ្ញា?»

ពៅបញ្ញាងាកមុខចេញតែខ្លួននាងត្រូវទាញទៅកាន់តែជិតទ្រូងនាយ នាងនិយាយបន្ត៖

«ខ្ញុំចាំជានិច្ចអ្វីដែលលោកបានជួយគ្រួសារខ្ញុំ! ថ្ងៃក្រោយលោកឲ្យខ្ញុំធ្វើយ៉ាងណាខ្ញុំធ្វើតាមតែលោកត្រូវរក្សា សន្យាកុំឲ្យលោកប៉ាជ្រាប!»

ស្មានថានាងទន់ភ្លន់ចេញពីបេះដូង ដឹងអីមានភ្ជាប់លក្ខខណ្ឌមកបន្ថែមសោះ។ អ្នកប្រុសស្រាប់តែកើតចិត្តច្រណែនចង់ឈ្នះសូម្បីតែឥទ្ធិពលខ្លួន ប្រៀបធៀបជាមួយឪពុកនាង។ គេជ្រួញចិញ្ចើម ព្រោះមិនពេញចិត្តដែលនាងគិតពីឪពុកហួស ។ ស្រីស្លូនបន្ថឹមកបន្ថែម៖
«លោកឲ្យខ្ញុំទៅវិញទៅ! ថ្ងៃក្រោយខ្ញុំនឹងមកទៀត! បើលោកគ្មានពេល ខ្ញុំនឹងជួយស្រោចផ្កានោះឲ្យ!»
គេនៅស្ងៀមក្នុងចន្លោះរវាងភាពអណ្ដែតអណ្ដូងនិងការច្រណែនប្រចណ្ឌ។
«ក្នុងបេះដូងនាង ខ្ញុំនិងប៉ាឃាតកររបស់នាង អ្នកណាធំជាងពៅបញ្ញា?»គេសួរខ្លួនឯងស្ងាត់ៗទោះបីមានចម្លើយសម្រាប់ ខ្លួនហើយក៏ដោយ។
«ខ្ញុំមានលុយឯណាជួលអ្នកនាងធំមកស្រោចផ្កាទៅ?»
«គឺស្ម័គ្រចិត្ត! ខ្ញុំស្ម័គ្រចិត្តធ្វើ! ខ្ញុំថាម៉េចគឺអញ្ចឹងហើយ!»
គេរវើក្មេកសម្លឹងនាងដែលទើបតែងើបមុខមក។
ហួត ស៊ីវ និងលេខាប៉េងប្រាកដឆ្លាតមួយជីវិតបែរមកគិតខុសមួយគ្រា ដែលស្មានថាកំហឹងដែលគេប្រើល្បិចកសាងឡើងមួយលើកជាពីរលើកនោះ អាចកាត់ផ្ដាច់មនោសញ្ចេតនាស្នេហាប្រុសស្រី ដែលកប់ជ្រៅក្នុងបេះដូងតាំងពីអតីតកាលច្រើនឆ្នាំមកហើយនេះ។

នៅចំពោះមុខនាង គ្រាន់តែនាងស្លូតបូតបន្តិចអ្នកប្រុសដ៏គ្រោតគ្រាតស្រាប់តែទន់ជំហរ ដល់ថ្នាក់ភ្លេចរឿងឆាកល្ខោនអស់នោះឯកឯងទៅហើយ ទម្រាំនាងសើចដាក់គេតែបន្តិចទៀតមិនដឹងថាគេអាចធ្វើអ្វីខ្លះ ដើម្បីនាងទេ។
យុត្តនាមិនមែនមិនដឹងអំពីស្ថានភាពដ៏ពិបាកជួយរបស់ខ្លួនទេ នាយរវើក្មេករិះគិតម្នាក់ឯង៖
«ស្រីឆ្កួតនេះមានមន្តអាគមទាញចិត្តមនុស្សប្រុសអញ្ចឹងសោះ បានជាខេមរិទ្ធិទៅនៅខាងណោះមិនបានប៉ុន្មានក៏បាក់លើនាងបាន! នាងសាហាវពេកហើយពៅបញ្ញា!»
គេនិយាយបន្លប់ចិត្តដ៏ទន់របស់ខ្លួន៖
«កុំតែនាងទៅវិញរកវិធីសម្លាប់ខ្ញុំបំបិទមាត់ឬដាក់អន្ទាក់ញាត់ខ្ញុំចូលគុកនោះទៅ វាបានទៅហើយ!»
គេបើកភ្នែកសម្លឹងនាងដោយអាក់អន់ចិត្ត។ ស្រីតូចបើកភ្នែកគ្រលួង៖

«ខ្ញុំមិនដែលធ្វើអញ្ចឹងទេយុត្តនា!»
គេសើចចុងមាត់ហាក់ជូរចត់៖
«នាងក៏ដោយ អាបងសំអុយរបស់នាងក៏ដោយ ! កុំដេកសង្ឃឹមថាបានសម្រេច! ចាំមើលតែដល់ពេលខ្ញុំលេងវិញ ខ្ញុំសងឲ្យគ្រប់!»
ពៅបញ្ញាដកដង្ហើមធំ។ នាងនិយាយទាំងពិបាកចិត្ត៖
«លោកឈប់គិតរឿងអាក្រក់ៗទៅ! ធ្វើអាក្រក់អត់មានបានអ្វីមកវិញទេ! គឺបំផ្លាញខ្លួនឯង»
តែគេសម្លឹងមុខនាងវិញជាប់ធ្វើឲ្យនាងទៅជាទើសទាល់។
«ម៉ាក់ខ្ញុំខូចយូរហើយ! កំពុងមានគេចង់មកធ្វើម៉ែខ្ញុំមែនអត់?»
ស្រីតូចហួសចិត្តនឹងសម្ដីនេះ នាងភ្ញាក់ពេកទៅជាសើចខឹកៗលែងនិយាយ....ហើយងើបមុខមើលមុខគេថាអ្វី ទៅដែលឲ្យគេរកនឹកឃើញពាក្យអស់នេះមកនិយាយនឹងនាងទៅរួច។

«នាងកំពុងធ្វើឲ្យខ្ញុំឆ្កួតហើយពៅបញ្ញា!»
គេគិតផងសម្លឹងនាងមិនដាក់ភ្នែកហើយហោះហើរអារម្មណ៍ស្ទើរឆ្កួត វង្វេង។ នេះជាសំណើចដែលគេខានឃើញ១៥ឆ្នាំមកហើយ តើវាស្អាតកម្រិតណាទៅ។ គេប្រឹងគំរោះគំរើយបន្លប់ខ្លួនឯង៖
«សើចអី? អួះ? ល្អសើចណាស់? មានអីគួរឲ្យសើចទៅ?»
ស្រីស្អាតទប់សំណើច នាងប្រឹងពន្យល់គេ៖
«លោកគិតខុសតែខ្លួនឯង! ចំណែកបងប្រាថ្នា ក៏គ្មានរឿងអីត្រូវមកពាក់ព័ន្ធដែរ រឿងលុយ១១លាន គាត់គ្រាន់តែចង់ឲ្យប៉ានិងម៉ាក់ជុំគ្នាវិញ!»
«កោតតែនាងជឿវា»គេគិតតែមិននិយាយចេញមកទេ ព្រោះរបៀបដែលនាងជឿលើបងប្រុសនាងគឺដូចបេះបិទនឹងកាលដែលនាងជឿ ថាប៉ានាងមិនបានសម្លាប់មនុស្សដូច្នោះដែរ។ អ្នកដឹងថាទោះនិយាយយ៉ាងណាក៏នាងមិនយល់ ម្ល៉ោះហើយគេប្ដូរប្រធានបទហើយសម្លុតនាងតិចៗដោយមិនដកភ្នែកចេញ ពីនេត្រាខ្មៅយង់ទាំងសងឡើយ៖
«អត់ខ្វល់! សំខាន់នាងខ្លួនឯងមេធាវី! នាងនិយាយអីយប់នេះត្រូវចាំសម្ដីខ្លួនឯង បើនាងស្លូតនាងនឹងបានស្លូត តែបើនាងចង់លេងល្បិច ខ្ញុំមានល្បិចកំដរវិញ!»
គេរាងមានះ នាងចាប់រាងក្ដៅស្លឹកត្រចៀក។
«ក្រៅពីគំរាមកំហែងសម្លុត តើគេនេះនៅចេះវិធីផ្សេងទេ?»

នាងងាកមុខឈានជើងចេញលែងខ្វីឆ្លងឆ្លើយព្រោះចាប់អន់ចិត្ត ប៉ុន្តែគេចាប់កដៃនាងមកវិញ។

ទោះបីខ្នងនឹងខ្នងទល់គ្នា នាងឮសំណួរគេលាន់មក៖

«ប្រុងទៅវិញរបៀបម៉េច?»

ស្រីតូចមិនឆ្លើយហើយអ្នកប្រុសក៏ទាញនាងឲ្យអង្គុយលើកៅអីផ្តៅដែលរៀបជាជួរក្បែរនោះ។ គេថយទៅក្នុងកូនបន្ទប់ក្នុងពេលនាងរវេរភ្នែកសម្លឹងជុំវិញទីនេះទាំងក្រៀមក្រំ។

«មនុស្សស្រស់ម្ដីយ៉ាប់នេះឧស្សាហ៍មកទីនេះ ប្រហែលគេនឹកប៉ាម៉ាក់គេហើយមើលទៅ!»

យុត្តនាចេញមកវិញជាមួយស្បែកជើងមួយគូក្នុងដៃ។

គេទម្លាក់ខ្លួនអង្គុយក្បែរជើងនាងហើយស៊កឲ្យក្រោមភាពស្រឡាំងកាំង របស់ស្រីអ្នកច្បាប់។ ស្បែកជើងនោះទាបហើយរលុងតែទន់ល្មើយអាចថាមានក្ដីសុខជាងដើរជើង ទទេ។ គេសើចពេលដែលប្រអប់ជើងតូចត្រូវបង់សម្រស់ដោយសារស្បែកជើងហួសសម័យ នោះ។

«របស់ម៉ាក់ខ្ញុំ! សំណាងហើយដែលឲ្យខ្ចីពាក់!»

នាងក៏នឹកឃើញភ្លាមដល់ស្បែកជើងដ៏ប្រណិតរបស់ខ្លួនដែលបាត់ទៅ ថ្មីៗនេះដោយសារគេបង្ខំមកទាំងប្រទាំងប្រទើស។ នាងខាំមាត់តិចៗសម្លក់គេចំពេលគេងើបមុខមក។

ជាលើកទីមួយដែលយុត្តនាឃើញកុលស្ត្រីត្រកូលខ្ពស់ចេះធ្វើមុខឌឺ។ គេញញឹមឌឺវិញ៖

«សមដែរតើ! សាកដើរមើល៍!»

ស្រីតូចក្ដាប់មាត់និយាយ៖

«កុំស្មានថាបានរួចខ្លួនងាយ! លោករកទិញស្បែកជើងមកសងខ្ញុំឲ្យបានឆាប់! បើមិនអញ្ចឹង....»

ស្រីស្អាតបញ្ឈប់ប្រយោគកណ្ដាលទី ព្រោះបាតដៃគេទាំងពីរលើកមកក្រសោបលើចង្កេះនាង។ ដោយសារនាងកំពុងអង្គុយផង បើគេជ្រុលតែបន្តិចទៀតបាតដៃនោះប៉ះត្រគាកនាងមិនខាន។ មេធាវីតូចច្រឡឹង ក្រហមមុខងាំងពេលដែលកំពុងអៀនខ្មាសហើយក្រឡេកទៅប៉ះកែវភ្នែកទាំង ទ្វេរបស់នាយ។

«បើមិនអញ្ចឹងយ៉ាងម៉េច?.....»

នាងមិនឆ្លើយតែត្រូវពន្លឺភ្នែកអ្នកកំលោះទាក់ទាញបាន។ នាងសម្លឹងគេទាំងលើកចិញ្ចើមឡើងលើព្រោះឆ្ងល់ហេតុអ្វីគេដៃដល់ យ៉ាងនេះ។ ម្រាមដៃទាំងសងរបស់នាងដាក់ទៅលើបាតដៃគេដើម្បីទាញចេញ តែយុត្តនាត្រៀមបានស្រេចបាច់ក្នុងការចាប់ឃុំទាំងប្រអប់ដៃនាង

ធ្វើឲ្យពៅបញ្ញារបូតចោលទូរសព្ទទៅក្បែរនោះ។
«ចង់ចាំមើលគេប្ដឹងឡើងតុលាការដោយសារធ្វើជ្រុះស្បែកជើងកូនស្រីគេដែរហ្នឹង!»
ស្រីស្អាតបូញមាត់ហាក់ខឹងនឹងចរិតឡិបឡុបនេះ នាងនៅស្ងៀមព្រោះរើតែដៃក៏មិនរួចតែភ្នែកសម្លក់គេមិនប្រាកដថា ស្អប់ តែក្នាញ់គេគឺច្បាស់ជាង។ គេងើបមុខមកនិយាយបន្តដោយសម្លឹងបបូរមាត់នាងដែលខាំតិចៗព្រោះ ក្នាញ់នាយ៖
«ដល់ពេលចៅក្រមសួរ ចាំឆ្លើយតែហ្មងទៅថាមកពីម្ចាស់ស្បែកជើងហ្នឹងជាមេធាវីដឹង ច្បាប់ល្មើសច្បាប់ ពូកែឪប្រុសៗពេកបានជាគេទ្រាំមិនបានចាប់បញ្ចូលឡានរបូតស្បែក ជើងហ្នឹង!»
នាងរអ៊ូតិចៗស្ទើរមិនចង់ឮ៖
«យ៉ាប់ណាស់!»
យុត្តនាឆ្លើយភ្លែត៖
«អញ្ចឹងបានមួយគូហើយ ព្រោះយើងហ្នឹងក៏យ៉ាប់ដែរ!»
«ប្រុសចរិតស្រី! តមាត់គ្មានបាត់មួយម៉ាត់ណាទេ!»នាងគិតម្នាក់ឯងហើយលែងនិយាយអ្វីព្រោះបើនឹងហាមួយទៀតច្បាស់ជាគេមានចម្លើយមកវិញ១០ដងពីលើនោះ មិនខាន។ ឃើញនាងនៅសម្លឹងគេលែងរើបម្រះព្រោះរើមិនរួចយុត្តនាបង្អន់ភាព មានះ នាយលែងដៃស្រីតូចថ្នមៗហើយក្រោកឡើងចំពោះមុខនាងបន្ទាប់មកទាញ នាងឲ្យក្រោកដែរ។ ស្រីស្អាតលូកដៃរើសទូរសព្ទក្បែរខ្លួនមកកាន់ដោយដើរតម្រង់ទៅមាត់ ទ្វារចេញ។
អ្នកប្រុសធនាគារដើរតាមពីក្រោយនាងទៅដែរ ព្រោះបំណងនាយគឺជូននាងទៅផ្ទះ ប៉ុន្តែមកដល់ទ្វារហៀបនឹងចាក់សោ គេស្រាប់តែនឹកឃើញដល់ឆាកដួលលើគ្នាមុននេះ។ គេសើចឃឹកៗហើយលូកដៃទៅទាញកដៃនាងមកវិញ។ នារីងាកមកដោយកែវភ្នែកស្រទន់ធ្វើឲ្យភាគីខាងប្រុសកាន់តែបាន ចិត្តក្នុងការលេបខាយ។ នាយនិយាយខ្សឹបៗទាំងបង្ហាញទំនុកចិត្ត ១០០ភាគរយលើផ្ទៃមុខ៖
«យប់នេះច្បាស់ជាមានអ្នកខ្លះដេកមិនលក់នឹកឃើញរឿងផ្អែមៗនៅផ្ទះនេះ មែនអត់!»
ភាពអៀនប្រៀនលំអផ្ទៃមុខមេធាវីដោយកម្ដៅភាយៗ ដែលប្រែស្បែកនាងឲ្យទៅជាក្រហមព្រឿងៗ។ នាងគេចភ្នែកចេញ ហើយតបវិញភ្លាម៖
«នឹកឃើញជាងគេ គឺវិនាទីដ៏អាក្រក់ដែលត្រូវគេបង្ខំអូសឡើងឡាន បណ្ដេញចេញប្រជាប់ប្រភីងកណ្ដាលពិធីនោះអី! »
អ្នកប្រុសរេភ្នែកសម្លឹងសាច់ស្មាសរលោងរបស់នាងហើយបណ្ដើរនាងដើរត្រឹកៗចុះទៅក្រោម

ឯមាត់ក៏មិនភ្លេចបន្ត៖
«ចុះពូកែពាក់អាវចំហសាច់បង្អួតប្រុសៗធ្វើអី? ចូលចិត្តណាស់អារឿងបង្ហាញឫកឲ្យគេមកសុំរលាក់ដៃ!»
ពៅបញ្ញាលែងត នាងដើរកាន់តែលឿនចុះមកដល់ខាងក្រោមដោយលើកទូរសព្ទបម្រុងវាយរក អ្នកបើកឡាន ដឹងអីទូរសព្ទត្រូវបាតដៃយុត្តនាផ្ទប់ជាប់។
«កុំបាច់ហៅ! មិនចង់ឲ្យអ្នកណាស្គាល់កន្លែងនេះទេ!»
ស្រីស្អាតងើបមុខសម្លឹងនាយ នាងមិនចង់ទេក្នុងការឡើងឡានប្រុសម្នាក់នេះទៀត តែនាងដឹងថា គេក៏មិនមែនធ្វើតាមនាងស្រួលៗដែរ។ អស់កម្លាំងនឹងជជែកតវ៉ា អស់កម្លាំងនឹងស្តាប់ពាក្យគ្មានហេតុផលរបស់គេ នាងដកដង្ហើមធំទម្លាក់ទូរសព្ទចុះហើយដើរឡើងឡានគេដែលត្រូវបានបើក ទទួលនាងយ៉ាងគួរសមខុសពីកាលពេលមក។

មិនទាន់ឈានជើងដល់ជំនិះផង ហ្វាឡានមួយផ្សេងទៀតបាញ់វ៉ាវមកចំពីមុខទន្ទឹមនឹងស្នូរបោលមកដល់ លាន់រំជួយជ្រែកកាត់ស្បែរាត្រី។
ពៅបញ្ញាចាំងភ្នែកត្រូវលើកដៃបាំងដែលបន្ទាប់មកនាងស្គាល់ថាជា រថយន្តអ្នកផ្ទះនាង ដែលទើបតែស្លន់ស្លោមកដល់។ យុត្តនាប្តូរទឹកមុខពីទន់ភ្លន់ទៅជាសើចចំអក។
គេឱនមកខ្សឹបដាក់នាងតិចៗ៖
«ពូកែរើសបរិវារដល់ហើយ! តាមស្អិតឲ្យដូចស្រមោច»
ហ្វាភ្លើងទម្លាក់រួចរលត់ធ្វើឲ្យនាងក្រមុំអាចមើលស្គាល់ថា អ្នកបើករថយន្តគឺជំនួយការរិទ្ធិ។ នាងចាប់រកាំចិត្តព្រោះនៅមិននៅមកឲ្យអ្នកផងឃើញនាងនៅពីរនាក់ ប្រុសម្នាក់នេះកណ្តាលរាត្រីស្ងាត់សូន្យ។
...តែពៅបញ្ញារឹតតែត្រូវក្តុកចិត្តទៅទៀត គឺក្រៅពីរិទ្ធិ នៅមានមនុស្សម្នាក់ផ្សេងទៀតដែលចុះពីទ្វារខាងស្តាំហើយដើរធ្ងន់ ៗសំដៅមក។ ទម្ងន់ជើងរបស់គេបង្ហាញថា គេស្ពាយកំហឹងមកតាម ។
នោះគឺជំនួយការដ៏ស្មោះត្រង់ តែចិត្តវិញមិនសូវធ្ងន់ដូចដំណើររបស់គេឡើយ ។
«បងណៈ?»
ឃើញមុខដ៏ក្រញូវរបស់ជំនួយការវណ្ណៈដែលងាកមកសម្លឹងខ្លួន យុត្តនាដឹងហើយថាជំនួយការសង្ហាម្នាក់នេះកំពុងមានចិត្តហួងហែង ចៅហ្វាយស្រីដល់កម្រិតណា។ គេគ្រលាស់

អណ្ដាតលេងក្នុងចេតនាឌឺដងបញ្ឆោះកំហឹងក្នុងចិត្តម្នាក់ នោះ ហើយទើបដាក់ភ្នែកទៅមើលជំនួយការទីពីរដែលនៅអង្គុយក្នុងឡាននៅ ឡើយ។
«ឯងឆេះដុំដូចអាមួយនេះដែរទេរិទ្ធិ បានជាអង្គុយក្នុងនោះមិនចុះមករកស្រីស្អាតរបស់ឯង?»
សំឡេងអ្នកនាងតូចគ្រួសារប៉ែនពេជ្រលាន់មកតិចៗ៖
«លោកឡើងទៅសម្រាកទៅយុត្តនា! ខ្ញុំទៅវិញជាមួយពួកគេ!»
«ចុះមកពីរនាក់ឡើងទៅវិញតែម្នាក់ដេកលក់កើតដែរ?»
គេឆ្លើយភ្លាមហើយរេភ្នែកមករកនាង គេចង់និយាយអ្វីបន្ថែមទៀតដែរ តែពន្លឺភ្នែកស្រីដូចជាមានន័យអង្វរករស្រេចហើយថា កុំឲ្យអ្នកបង្ករឿងអាម៉ាស់ដល់នាងច្រើនជាងនេះទៀត ទើបគេព្រមទប់ចិត្តមកវិញលែងនិយាយស្ដី ដឹងអីស្រាប់តែជំនួយការនោះជះសម្ដីមកយ៉ាងអន្ទះសា៖
«អ្នកណាធ្វើអីអ្នកនាង?»
ស្រីតូចនៅទីទើររកពាក្យឆ្លើយមិនចង់កើតសោះ ស្រាប់តែជំនួយការវណ្ណៈបន្ថែមមកផ្ទួនៗ៖
«ខ្ញុំនៅទីនេះហើយ អ្នកនាងមិនបាច់ក្រែងចិត្តអ្នកណាទាំងអស់!»
ស្រីក្រមុំរេភ្នែកទៅរកបុរសដែលទើបតែឱបក្រសោបនាងមុននេះ ឃើញគេបែរខ្នងដើរទៅបើកទ្វាររថយន្តខាងក្រោយ ដោយមិនរវល់នឹងសម្ដីឌឺដងរបស់វណ្ណៈ នាងកាន់តែពិភាល់ក្នុងចិត្តសួរខ្លួនឯងក្នុងចិត្ត៖
«លោកមិនមែនដល់ថ្នាក់ មានកាំភ្លើងក្នុងឡាន ហើយទៅយកវាមកបាញ់បោះផ្ដើលគេឯងទេដឹងយុត្តនា?»
ដោយសារគេសោះកក្រោះពេកឆេវឆាវពេកក្រអឺតក្រអោងពេក បានជានាងកាន់តែបុកពោះរាល់ពេលជំនួយការប៉ានាងនិយាយស្ដីឌឺដងគេ តែនាងចម្លែកក្នុងចិត្តវិញ ព្រោះយុត្តនាត្រលប់មកជាមួយអាវធំក្នុងដៃ។
នោះជាអាវដែលគេគ្របដោយបង្ខំទៅកាន់ពិធីជប់លៀងក្នុងនាមជា ទេសាភិបាលវ័យក្មេង តែដោះវាចោលក្នុងពេលគេចាកចេញពីកម្មវិធីនោះមកជាមួយនាង។
បុរសលើកអាវគ្របលើស្មាទាំងសងដ៏ស្អាតផូរផង់របស់ពៅបញ្ញាក្រោម ពន្លឺភ្នែកក្រហមឆៅរបស់ជំនួយការដែលនៅចំពោះមុខ។ គេញញឹមដាក់នាងជាមួយវាចាស្រាលៗ៖
«មេឃត្រជាក់ណាស់ប្រយ័ត្នផ្ដាសាយ!»
ស្រីស្អាតយល់ថាស្រីក្រមុំត្រកូលប៉ែនពេជ្រមិនសមបើថាទទួលអាវ មនុស្សប្រុសណាមកគ្រប

ដណ្តប់លើរាងកាយកណ្តាលចំណោមមនុស្សម្នា ដូច្នេះទេ ពិសេសគឺម្ចាស់អាវជាមនុស្ស របៀបនេះទៀត ប៉ុន្តែរវាងការអៀនខ្មាសអង្គរក្សទាំងទ្វេនឹងធ្វើឲ្យយុត្តនាអាក់ អន់ចិត្ត នាង សុខចិត្តរើសយកជម្រើសទីមួយទៅចុះ។

ស្រីស្អាតនៅឈរទ្រឹងក្នុងពេលដែលជំនួយការរិទ្ធិនៅឯចង្កូតឡាន ងាកមុខគេចចេញមិនចង់ឃើញទិដ្ឋភាពផ្អែមល្ហែមដែលយុត្តនាសម្តែងនោះ។
«ហើយនេះសោផ្ទះលើ! មកពេលណាក៏បាន! ស្វាគមន៍ជានិច្ច!»
នារីអ្នកច្បាប់ឱនសម្លឹងបាតដៃគេដែលទ្រចាំនាងឲ្យទទួលសោ។ នាងងើបមុខមើលគេដោយមិនដឹងខ្លួន គេនៅតែចំណាយពន្លឺភ្នែកឱ្យដងមករកនាងធ្វើឲ្យនាងងាកមុខចេញលែង ហ៊ានទទួលភ្នែកគេទៀត។
ស្រីស្រស់បង្វែរខ្លួនចាកចោលគេតែនាងសួរខ្លួនឯងស្ងាត់ៗក្នុងពេលឈានជើងមួយៗតម្រង់ទៅរករថយន្ត៖
«គេពិតជាយកចិត្តទុកដាក់នឹងយើង? គេចង់ធ្វើអញ្ចឹងចេញពីបេះដូង ឬគេគ្រាន់តែចង់ដុតបងវណ្ណៈបន្ថែម?»
នាងដើរមិនបានពីរបីជំហានក៏ឮសន្ទឹកបិទទ្វារឡានគ្រាំងតាម ទម្លាប់ពិបាករករបស់គេ បន្ទាប់មកការរឺយ៉េឡានរំពងគ្មានក្រែងចិត្តអ្នកណានិងចុងក្រោយការ បោលចេញទៅបាត់ស្រមោលក្រោមស្រទាប់សន្សើមស្រអាប់ក្រាស់។
ស្រីតូចដកដង្ហើមយូរបន្ធូរភាពតឹងតែងហើយបន្តដំណើរតម្រង់រថយន្ត...។

រថយន្តលូនដល់ផ្ទះប៉ែនពេជ្រ ដោយនៅជាប់តាមផ្លូវបុរសទាំងពីរគ្មានអ្នកណានិយាយអ្វីៗមួយម៉ាត់ឡើយ។
រថយន្តឈប់ដោយមានអ្នកបម្រើចំណាស់រត់មកទទួលដល់ទ្វារ។ រិទ្ធិរភ្នែកសម្លឹងអ្នកនាងតូចដែលមិនគង់សូម្បីស្បែកជើងកែង ចោត។
គេនឹកចម្លែកៗក្នុងចិត្តថាមានអ្វីៗកើតឡើងរវាងនាង និងយុត្តនាកាលពីជាងមួយម៉ោងមុននេះ។
ចុះដល់កម្រាលឥដ្ឋ នាងស្រាប់តែដំអក់ហើយបែរក្រោយមករកជំនួយការទាំងទ្វេរបស់ឪពុក៖
«អរគុណបងណៈ បងរិទ្ធិ ដែលអំពល់ទាំងយប់ដោយសាររឿងនេះ! ហើយ.....»
នាងនៅទីទើររិទ្ធិក៏ជួយបង្ហើយ៖

«អ្នកនាងសម្រាកទៅ ពីរនាក់ខ្ញុំមិននិយាយអ្វីឲ្យជ្រាបដល់លោកឧកញ៉ាទេ!»
នៅតែជាគេដែលគួរឲ្យនាងកក់ក្ដៅជានិច្ចកាល។ ស្រីស្រស់ធូរទ្រូង នាងរេភ្នែកមករកជំនួយការមួយទៀតដែលនៅក្រញូវនៅឡើយ នាងដឹងថាគេឈឺឆ្អាលនឹងនាងហើយខឹងនឹងយុត្តនាជាខ្លាំង ប៉ុន្តែនាងមិនអនុញ្ញាតគេក៏មិនហ៊ានបង្ករឿង។ ស្រីស្រស់ដកដង្ហើមយូរហើយនិយាយមួយៗ៖
«បងណៈ ឈប់គិតច្រើនទៅ ម្នាក់នោះគេមិនបានធ្វើអីអំពល់ដល់ខ្ញុំទេ!»
វណ្ណៈដៀងភ្នែកមករកជើងរបស់នាងជាសញ្ញារិះគន់ថា នាងនិយាយខុសពីការពិតតែនាងខំបន្ថែមបញ្ចប់រឿង៖
«ស្បែកជើងកែងនោះជ្រុះពេលខ្ញុំឡើងឡានគេ ក៏គ្មានពេលត្រឡប់ក្រោយរើស! យប់ហើយ! ខ្ញុំមិនចង់ឲ្យពួកបងមកពិបាកចិត្តដោយសាររឿងអស់នេះទេ! រាត្រីសួស្ដី!»

នាងឈានតម្រង់ទៅរកអ្នកបម្រើស្រីវ័យចំណាស់ ដែលនៅឈរចាំប្រណិប័តន៍នៅឯមាត់ទ្វារធំ។គាត់និយាយមករកនាង ដោយទឹកមុខព្រួយបារម្ភ៖
«អ្នកនាងពៅអីក៏យប់ជ្រៅម្ល៉េះនេះ? លោកឧកញ៉ាសម្រាន្តលក់ហើយតែលោកផ្ដាំថា អ្នកនាងមកដល់ពេលណាឲ្យជម្រាបលោក!»
ស្រីស្អាតខំញញឹមបំបាត់ភាពស្មុគស្មាញលើវង់ភក្ត្រ តែនាងសម្គាល់ឃើញថាភ្នែកស្ត្រីនោះរេមករកអាវមនុស្សប្រុសដែល កំពុងគ្របដណ្ដប់លើស្មាទាំងសងរបស់នាង។ ស្រីតូចប្រែទឹកមុខតែនាងខំបន្លប់បរិយាកាសមកវិញ៖
«ខ្ញុំឡើងទៅរកលោកប៉ាខ្លួនឯង មីងសម្រាកចុះ!»
ពៅបញ្ញាដោះស្បែកជើងយកទៅទុកក្នុងទូខ្លួនឯង ហើយចាកចេញទៅជាន់ខាងលើភ្លាមៗ ព្រោះចង់គេចចេញពីក្រសែភ្នែករបស់ ពួកគេហើយក្លិនខ្លួនបុរសម្ចាស់ផ្ទះជាន់ទីបួននៅតែជិតដាមមកពេញ ខ្លួនប្រាណនាង ។
តើវាជ្រាបចូលដល់បេះដូងមេធាវីដែរឬយ៉ាងណានូវកាយវិការម្ដងសោះកក្រោះ ម្ដងទន់ភ្លន់របស់អ្នកលេងមុខស្រស់?

មកដល់ក្នុងបន្ទប់ខ្លួនទើបនាងដកដង្ហើមបានពេញលេញ លែងត្បិតត្បៀតដូចមុន ព្រោះថានៅ ទីនេះមានតែនាងម្នាក់ឯងលែងមានអ្នកតាមសម្គាល់មើលទៀត។ ស្រីតូចទម្លាក់ទូរសព្ទចោលលើពូក...ទាំងមានអារម្មណ៍ថាអស់កម្លាំងទន់ ល្មើយ.....

នៅក្នុងផ្ទាំងកញ្ចក់ អាវធំរបស់គេនៅគ្របលើកាយស្រី ធ្វើឲ្យនាងងាកទៅសម្លឹងភ្លៀកៗ ហើយសន្សឹមៗលើកម្រាមដៃស្ទាបវត្ថុគ្មានវិញ្ញាណនោះថើៗ។ ចិត្តនាងដណ្ដឹងសួរឡើង៖ «គេពិតជាគំរោះគំរើយបង្ខំយើងគ្មានយោគយល់នៅឯពិធី ព្រោះតែគេប្រចណ្ឌថាយើងពាក់អាវវាលបង្អួតអភិជនក្មេងៗ? គេនោះឬដែលមកប្រចណ្ឌយើង? ហើយយើងជាកម្មសិទ្ធិរបស់គេពីអង្កាល់?»

នាងទាញអាវនោះចុះយឺតៗរួចសម្លឹងស្មាទាំងសងរបស់ខ្លួនក៏មិនឃើញថា មិនវាលហួសហេតុអ្វីដល់ថ្នាក់អាសអាភាសនោះដែរ។

នាងស្រាប់តែនឹកឃើញដល់ម្រាមដៃរបស់គេដែលអង្អែលថ្នាក់ថ្នមសាច់ស្មា នោះ ហាក់ដូចចង់ប្រាប់នាងថា គេជាកម្មសិទ្ធិនៅទីនោះ ហើយនាងក៏នឹកឃើញដល់ពេលដែលនាងបង្ខំចិត្តងើយទៅថើបបបូរមាត់គេ....

....ស្រីតូចលើកដៃជូតមាត់ខ្លួនដោយភាពអៀនខ្មាស ហើយគេចមុខលែងហ៊ានមើលខ្លួនឯងក្នុងកញ្ចក់ជាមួយស្នូរដង្ហើមដក ញាប់ៗព្រោះតែការខ្មាសអៀនកើតឡើងពេញទំហឹង....

«កោតតែឯងធ្វើទៅរួចពៅបញ្ញា?»នាងជ្រួញចិញ្ចើមបិទភ្នែកបន្ទោសខ្លួនឯង។

បរិយាកាសស្ងប់ស្ងាត់កន្លងទៅ នាងបើកភ្នែកហើយរេមកសម្លឹងទូរសព្ទដែលនៅក្បែរកាយ «ថ្មីរណោះ គេនៅឯណាហើយធ្វើអ្វី? គេទៅគេងនៅបឹងកេងកងមែនដែរទេ? មិនប្រាកដទេ គេអាចថាទៅលេងកន្លែងប្រុសៗណាផ្សេងក៏ថាបាន មនុស្សខិលខូចដូចគេ.....ចុះយើងទៅចំណាយពេលគិតពីគេបានប្រយោជន៍អី...? ឆ្កួតមែនពៅបញ្ញា!»

....នាងធ្មេចភ្នែកសាជាថ្មីមុនពេលបន្ថែមកម្លាំងឲ្យខ្លួនឯងដើរទៅ កាន់បន្ទប់ឪពុក។ នាងបង្អើបទ្វារតិចៗឃើញគាត់លង់លក់ឈឹងក្រោមចំហាយម៉ាស៊ីនត្រជាក់ ធីតាបកត្រលប់មករកទីដំណេកវិញ....

«ទោះយ៉ាងណា គ្រាន់ហើយដែលពេលនោះគេមិនបានបញ្ចេញសំឡេងមកកាន់ឪពុកនាង!» នឹកដល់វិនាទីនោះពេលនាងតែងតែភ័យបារម្ភ។...នាងនឹកដល់រឿងទាំងឡាយ ដែលអាចធ្វើឲ្យប៉ះទង្គិចដល់ទឹកចិត្តលោកឪពុករួមទាំងរឿងកូនប្រុស ធំរបស់គាត់និងរឿងដែលនាងនៅជំពាក់យុត្តនា...ទីបំផុតនាងក៏បានលាចាក ភាពស្មុគស្មាញមួយអន្លើហើយលង់លក់កំដររាត្រីកាល....

...ក្រោមជំនោររំភើយៗ ស្រីស្អាតលង់ទៅក្នុងសុបិនផ្អែមល្ហែមមួយចំនួនដែលរួមមាន ទាំងរូបរាង របស់អ្នកប្រុសទីមួយរបស់ ហួត ស៊ីវ ផង....

